



# សិក្ខាសាលាផ្សព្វផ្សាយស្តីពី

# សមិទ្ធផលធម្មនុញ្ញសម្រេចបានក្នុងរយៈពេល ៣០ឆ្នាំ

## ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ ឯកឧត្តម កែវ ពុទ្ធរស្មី សមាជិកក្រុមប្រឹក្សាធម្មនុញ្ញ

ខេត្តកំពង់ចាម ថ្ងៃពុធ ១៤រោច ខែទុតិយាសាឍ ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៧០

ត្រូវនឹងថ្ងៃទី១២ ខែសីហា ឆ្នាំ២០២៦

# បទបង្ហាញទី១

## គោលគំនិតរួមនៃខ្លឹមសារសមិទ្ធផលធម្មនុញ្ញ សម្រេចបានក្នុងរយៈពេល ៣០ឆ្នាំ

# សេចក្តីផ្តើម

- **គោលគំនិតនៅក្នុងបុព្វកថានៃរដ្ឋធម្មនុញ្ញ** (១)
  - គោលការណ៍ ៖ ប្រព័ន្ធប្រជាធិបតេយ្យសេរី
  - បំណងប្រាថ្នា ៖ ឯកភាពជាតិ អធិបតេយ្យជាតិ សន្តិភាព អារ្យធម៌អង្គរ ជាតិសម្បូររុងរឿង
  - គុណតម្លៃសង្គម ៖ បុរាណ និងសម័យ
- **បាវចនានៃព្រះរាជាណាចក្រកម្ពុជា**
  - ជាតិ
  - សាសនា
  - ព្រះមហាក្សត្រ

# ខ្លឹមសារគ្រឹះ០២ នៃរដ្ឋធម្មនុញ្ញ ត្រូវបានបង្កប់បង្កប់បង្កើតគ្នា



១- ការភ្ជាប់បង្កប់បង្កើតគ្នារវាងគុណតម្លៃទំនើបនិងគុណតម្លៃប្រពៃណីខ្មែរ (២)

-គុណតម្លៃទំនើប ជាមូលដ្ឋានគ្រឹះ " ប្រជាធិបតេយ្យ សិទ្ធិមនុស្ស នីតិរដ្ឋ " (៣)

-គុណតម្លៃប្រពៃណីខ្មែរ " ជាតិ សាសនា ព្រះមហាក្សត្រ " (៤)

-ការសិក្សាប្រៀបធៀបគុណតម្លៃទាំងពីរ (៥)

២- ពិសោធន៍បរទេស ៖ ការធ្វើទំនើបកម្មផ្សារភ្ជាប់នឹងតម្លៃប្រពៃណី (៦)

៣- ការសិក្សាករណីកម្ពុជា ៖ គុណតម្លៃនៃអត្តសញ្ញាណជាតិ ផ្សារភ្ជាប់ជាមួយលទ្ធិប្រជាធិបតេយ្យ (៧)

# ខ្លឹមសារគ្រឹះ០២ នៃរដ្ឋធម្មនុញ្ញ ត្រូវបានបន្សាំបន្សីគ្នា (ត)

## ៣.១-កត្តាមោទនភាពជាតិ

-ប្រវត្តិសាស្ត្ររុងរឿងនៃសម័យអង្គរ (សវ.ទី៩ ដល់សវ.ទី១៥) (៨)

-ប្រវត្តិសាស្ត្រនៃការធ្លាក់ចុះដុនដាបរបស់ប្រទេសជាតិ (៩)

-ព្រះពុទ្ធសាសនា (១០)

-ភាសា អក្សរ អក្សរសិល្ប៍បុរាណ សិល្បៈ។ល។

-ភាពធន់ខាងស្មារតីរបស់ជាតិ (១១)

## ៣.២-កត្តាសុខដុមនីយកម្មសង្គម (១២)

## ៣.៣-កត្តាឥទ្ធិពលនៃជំនឿផ្សេងៗ (១៣)

## ៤- ការបន្សាំបន្សីគ្នាត្រូវធ្វើដូចម្តេច?

- អនុសាសន៍ (១៤)

# សេចក្តីសន្និដ្ឋាន

## ▫ តួនាទីនៃគុណតម្លៃបុរាណក្នុងអតិក្រមបន្សាំបន្សុីគ្នា

- តួនាទីពង្រឹងអត្តសញ្ញាណជាតិ ព្រលឹងជាតិ ឯកភាពជាតិ ភាពធន់ខាងស្មារតីរបស់ជាតិ ចំពោះមុខបញ្ហាវិបត្តិធំៗ និងការវិវឌ្ឍឆាប់រហ័សរបស់ពិភពលោកបច្ចុប្បន្ន
- តួនាទីរួមចំណែកពង្រឹងចំណងទាក់ទងរវាងវប្បធម៌នៅនឹងកន្លែង (culture locale) ជាមួយលទ្ធិប្រជាធិបតេយ្យសេរី ដែលនាំទៅដល់ការជម្រុញការបញ្ច្រាបគុណតម្លៃធម្មនុញ្ញទំនើបទៅក្នុងស្មារតីនៃសង្គមខ្មែរ។


ព្រះរាជាណាចក្រកម្ពុជា
ក្រុមប្រឹក្សាធម្មនុញ្ញ
នីតិបូជនីយដ្ឋាន
វិមាន
រដ្ឋធម្មនុញ្ញ

# បទបង្ហាញទី២

## ខ្លឹមសារលម្អិតនៃសមិទ្ធផលធម្មនុញ្ញ សម្រេចបានក្នុងរយៈពេល ៣0ឆ្នាំ

# សេចក្ដីផ្ដើម

- រដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ គឺជា**សមិទ្ធផលប្រវត្តិសាស្ត្រ** (១៥)
  - កើតចេញពី**ឆន្ទៈរួមរបស់ប្រជារាស្ត្រខ្មែរ**គ្រប់និន្នាការនយោបាយ (១៦) (ឧទី១)
  - ត្រូវបានអនុម័តដោយសភាធម្មនុញ្ញនៅ**ថ្ងៃទី២១ កញ្ញា ១៩៩៣** និងត្រូវបានប្រកាសឱ្យប្រើនៅ**ថ្ងៃទី២៤ កញ្ញា ១៩៩៣** គឺជា**រដ្ឋធម្មនុញ្ញទី៦** (១៧)
- រដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ ជា**រដ្ឋធម្មនុញ្ញមានលក្ខណៈជឿនលឿន** (១៨)

# សេចក្តីផ្តើម (តចប់)



- **ក្នុងរយៈពេល៣០ឆ្នាំ** រដ្ឋធម្មនុញ្ញនេះត្រូវបានធ្វើ**វិសោធនកម្ម ១០លើក** និងបង្កើត**ច្បាប់ធម្មនុញ្ញបន្ថែមចំនួនមួយ (ឆ្នាំ២០២៥ វិសោធនកម្មលើកទី១១ ទាក់ទងនឹងការដកសញ្ជាតិ)**
  + វិសោធនកម្មត្រូវបានធ្វើ ៖
    - ស្របតាមនីតិវិធីកំណត់ក្នុងរដ្ឋធម្មនុញ្ញ (១៩) (ឧទី២)
    - ដើម្បីឆ្លើយតបនឹងតម្រូវការជាក់ស្តែងរបស់សង្គម
    - តាមរយៈការចរចាក្នុងស្មារតីបង្រួបបង្រួមផ្សះផ្សាជាតិ (២០)
    - ដោយជានាការគោរពលទ្ធផលនៃការបោះឆ្នោត (២១)
    - ក្នុងគោលដៅសំខាន់បំផុតសម្រាប់ដំណើរទៅមុខជាប្រក្រតីរបស់ប្រទេសជាតិ (២២)

# ១-កម្ពុជារក្សាការពារនិងគោរពលើកតម្កើងរបបរាជានិយមអាស្រ័យរដ្ឋធម្មនុញ្ញ

- ការបង្កើតឡើងវិញនូវរបបរាជានិយមអាស្រ័យរដ្ឋធម្មនុញ្ញក្នុងទម្រង់រាជានិយមជឿនលឿន ស្របនឹងបរិបទនៃសង្គមខ្មែរ។ (២៣)

- ព្រះមហាក្សត្រព្រះអង្គគង់ប្រថាប់ជាម្លប់ដ៏ត្រជាក់របស់ជាតិ ជានិមិត្តរូបនៃឯកភាពជាតិ និងនិរន្តរភាពជាតិ។ (២៤)

# ២-លទ្ធិប្រជាធិបតេយ្យសេរីពហុបក្សជាមូលដ្ឋានគ្រឹះនៃសណ្តាប់ធ្នាប់នយោបាយទំនើបនៃកម្ពុជា

របបប្រជាធិបតេយ្យសេរីពហុបក្សកម្ពុជាសម្រេចបានជំហានវឌ្ឍនភាពថ្មីៗ តាមរយៈការអនុវត្តនិយាមគោលការណ៍ធម្មនុញ្ញសំខាន់ៗមួយចំនួន ៖

**◻ និយាមគោលការណ៍ទី១ ៖**

- ប្រជាពលរដ្ឋខ្មែរជាម្ចាស់វាសនានៃប្រទេសជាតិរបស់ខ្លួន អំណាចទាំងអស់ជារបស់ប្រជាពលរដ្ឋ ដែលប្រជាពលរដ្ឋប្រើតាមរយៈរដ្ឋសភា ព្រឹទ្ធសភា រាជរដ្ឋាភិបាល និងសាលាជម្រះក្តី។ (២៥)
- អំណាចទាំងបីមានសមត្ថកិច្ចដាច់ពីគ្នា។ (២៦)
- ការអនុវត្តគោលការណ៍រក្សាតុល្យភាពទៅវិញទៅមករវាងអំណាចនីតិប្បញ្ញត្តិ និងអំណាចនីតិប្រតិបត្តិ។ (២៧)

# ២-លទ្ធិប្រជាធិបតេយ្យសេរីពហុបក្សជាមូលដ្ឋានគ្រឹះនៃសណ្ដាប់ធ្នាប់នយោបាយទំនើបនៃកម្ពុជា (ត)



## ◻ និយាមគោលការណ៍ទី២ ៖

- កម្ពុជាប្រតិបត្តិរបបបោះឆ្នោតពហុបក្សយ៉ាងទៀងទាត់តាមការកំណត់នៃច្បាប់ និងស្របតាមគោលការណ៍ប្រជាធិបតេយ្យ។ (២៨)

# ២-លទ្ធិប្រជាធិបតេយ្យសេរីពហុបក្សជាមូលដ្ឋានគ្រឹះនៃសណ្តាប់ធ្នាប់នយោបាយទំនើបនៃកម្ពុជា (ត)



## ▫ និយាមគោលការណ៍ទី៣ ៖

ការវិវត្តឈានទៀងជាជំហានៗនៃនយោបាយប្រជាធិបតេយ្យសេរីពហុបក្សនៅកម្ពុជា ៖

- **ជំហានវឌ្ឍនភាពទី១ ៖** ការវិវត្តនៃដំណើរប្រជាធិបតេយ្យនីយកម្មថ្នាក់ក្រោមជាតិ (២៩)
- **ជំហានវឌ្ឍនភាពទី២ ៖** ដំណោះស្រាយនៃការកែសម្រួលនីតិវិធីអនុម័តសម្រាប់ការបោះឆ្នោតផ្តល់សេចក្តីទុកចិត្តបង្កើតរាជរដ្ឋាភិបាល។ (៣០)
- **ជំហានវឌ្ឍនភាពទី៣ ៖** គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវបានកែទម្រង់ឱ្យមានកម្រិតជាស្ថាប័នធម្មនុញ្ញ និងមានការធានានូវភាពចម្រុះ និងអព្យាក្រឹតភាព។ (៣១)

# ២-លទ្ធិប្រជាធិបតេយ្យសេរីពហុបក្សជាមូលដ្ឋានគ្រឹះ នៃសណ្តាប់ធ្នាប់នយោបាយធំនើបនៃកម្ពុជា (ត)



- **ជំហានវឌ្ឍនភាពទី៤ ៖** ពង្រឹងសណ្តាប់ធ្នាប់គណបក្សនយោបាយនីមួយៗត្រូវគោរពរដ្ឋធម្មនុញ្ញ និងច្បាប់។ (៣២)
- **ជំហានវឌ្ឍនភាពទី៥ ៖** ការកំណត់សញ្ញាតិខ្មែរពីកំណើតតែមួយគត់ សម្រាប់មុខតំណែងមេដឹកនាំកំពូលនៃស្ថាប័នធម្មនុញ្ញរបស់ជាតិ។ (៣៣)
- **ជំហានវឌ្ឍនភាពទី៦ ៖** ការបំពេញចន្លោះខ្វះខាតនៃនីតិវិធីធម្មនុញ្ញ ដើម្បីធានាឱ្យស្ថាប័នកំពូលរបស់ជាតិ ជាពិសេសអំណាចនីតិប្រតិបត្តិដំណើរការប្រព្រឹត្តទៅដោយរលូននិងប្រកបដោយនិរន្តរភាព។ (៣៤)

# ២-លទ្ធិប្រជាធិបតេយ្យសេរីពហុបក្សជាមូលដ្ឋានគ្រឹះនៃសណ្ដាប់ធ្នាប់នយោបាយទំនើបនៃកម្ពុជា (តចប់)



## ◻ បញ្ហាប្រឈម ៖

- គណបក្សធំទាស់មួយចំនួនបានវិវត្តក្លាយជាចលនានយោបាយជ្រុលនិយម (៣៩)

# ៣-កម្ពុជាឈានឡើងជាសង្គមនីតិរដ្ឋ ជារដ្ឋប្រតិបត្តិតាមរដ្ឋធម្មនុញ្ញ និងច្បាប់

## ការប្រតិបត្តិតាមរដ្ឋធម្មនុញ្ញ និងច្បាប់ ៖

- **គោលការណ៍ទី១ ៖** កម្ពុជាតម្កល់រដ្ឋធម្មនុញ្ញ ជាច្បាប់កំពូលរបស់ប្រទេស។ (៣៦)
- **គោលការណ៍ទី២ ៖** អំណាចតុលាការ ជាអំណាចឯករាជ្យ។ (៣៧)
- **គោលការណ៍ទី៣ ៖** ក្រុមប្រឹក្សាធម្មនុញ្ញ ជាស្ថាប័នមានសមត្ថកិច្ចធានាការពារការគោរពរដ្ឋធម្មនុញ្ញ ដែលជាគ្រឹះនៃការកសាងនីតិរដ្ឋ។ (៣៨) (ឧទី៣)

# ៣-កម្ពុជាឈានឡើងជាសង្គមនីតិរដ្ឋ ជារដ្ឋប្រតិបត្តិតាមរដ្ឋធម្មនុញ្ញ និងច្បាប់ (តចប់)

## ▫ បញ្ហាប្រឈម ៖

- **បញ្ហាទី១ ៖** លក្ខណៈជឿនលឿននៃរដ្ឋធម្មនុញ្ញនិងនិន្នាការសកលនៃច្បាប់ថ្មីៗរបស់កម្ពុជា
- **បញ្ហាទី២ ៖** កម្រិតយល់ដឹងទូទៅអំពីយុត្តិធម៌ក្នុងក្របខ័ណ្ឌច្បាប់

# ៤-កម្ពុជាអនុវត្តប្រព័ន្ធសេដ្ឋកិច្ចទីផ្សារ ជារដ្ឋគោរព ការពាររបបកម្មសិទ្ធិឯកជន និងយុត្តិធម៌សង្គម

- ព្រះរាជាណាចក្រកម្ពុជាអនុវត្តប្រព័ន្ធសេដ្ឋកិច្ចទីផ្សារ (៣៩)
- គោលនយោបាយសង្គមកិច្ច (៤០)

# ការបន្តអនុវត្តការងាររបស់ក្រុមប្រឹក្សាធម្មនុញ្ញ ក្នុងរយៈពេល០៣ឆ្នាំចុងក្រោយ (២០២៣-២០២៦)



១- អនុស្សរណៈនៃការព្រមព្រៀងស្តីពីការដាក់បញ្ចូលបទប្បញ្ញត្តិគ្រឹះមួយចំនួនដែលមានចែងនៅក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ទៅក្នុងកម្មវិធីសិក្សា (៤១)

២- ពិធីគោរពរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាក្នុងស្មារតីនៃការរំលឹកខួប "ទិវាប្រកាសរដ្ឋធម្មនុញ្ញ" (៤២)

៣- ពិធីប្រគល់សម្ភាររដ្ឋធម្មនុញ្ញចម្លង ដើម្បីតម្កល់នៅរាជធានី-ខេត្ត ទាំង២៥ (៤៣)

# សេចក្ដីសន្និដ្ឋាន



- **ការអនុវត្តរដ្ឋធម្មនុញ្ញរយៈពេល ៣០ឆ្នាំ** ព្រះរាជាណាចក្រកម្ពុជាសម្រេចបាននូវសមិទ្ធផលដ៏ថ្លៃថ្លា ៖

  (១) ជារដ្ឋប្រតិបត្តិតាមរដ្ឋធម្មនុញ្ញ និងលទ្ធិប្រជាធិតេយ្យសេរីពហុបក្ស

  (២) ជារដ្ឋឯករាជ្យ អធិបតេយ្យ សន្តិភាព អព្យាក្រឹត អចិន្ត្រៃយ៍ និងមិនចូលបក្សសម្ព័ន្ធ រួមរស់ដោយសន្តិសហវិជ្ជមានជាមួយប្រទេសទាំងអស់លើសកលលោក ដោយអនុវត្តនយោបាយបរទេសឯករាជ្យផ្អែកលើច្បាប់

# សេចក្តីសន្និដ្ឋាន (តចប់)



(៣) ជារដ្ឋអនុវត្តសេដ្ឋកិច្ចទីផ្សារ គោរពការពារសិទ្ធិមនុស្ស និងយុត្តិធម៌សង្គមស្រប តាមគន្លងស្មារតីនីតិរដ្ឋជាគោល

(៤) ប្រជាពលរដ្ឋជាម្ចាស់វាសនានៃប្រទេសជាតិ មានជីវភាពរស់នៅដោយសុខដុមរមនា មានសិទ្ធិសេរីភាពទូលំទូលាយក្នុងការចូលរួមសកម្មភាពនយោបាយ សេដ្ឋកិច្ច សង្គម និងវប្បធម៌របស់ប្រទេសជាតិ និងរួមរស់ក្នុងភាពសុខដុមជាតិសាសន៍ និងសាសនាយ៉ាងល្អប្រពៃ។


សំណួរ ចម្លើយ

# កំណត់សម្គាល់

# (១) គោលគំនិតនៅក្នុងបុព្វកថានៃរដ្ឋធម្មនុញ្ញ



យើងប្រជារាស្ត្រខ្មែរ

ដែលធ្លាប់មានអារ្យធម៌ឧត្តុងឧត្តម ប្រទេសជាតិស្តុកស្តម្ភធំទូលាយ ថ្កុំថ្កើងរុងរឿង កិត្យានុភាពខ្ពង់ខ្ពស់ ភ្លឺថ្លៃចែងចាំងដូចពេជ្រពណ្ណរាយ,

បានធ្លាក់ខ្លួនដ៏សែនរន្ធត់ ក្នុងអំឡុងពីរទសវត្សចុងក្រោយនេះ ឆ្លងកាត់ទុក្ខសោកវិនាសអន្តរាយទ្រុឌទ្រោមឱនថយមហាសោកស្តាយ,

បានភ្ញាក់រលឹក ក្រោកឈរឡើង ចងបាច់ឆន្ទៈមោះមុត ប្តូរផ្តាច់រួបរួមគ្នា ពង្រឹងឯកភាពជាតិ រក្សាការពារ ទឹកដីកម្ពុជា អធិបតេយ្យថ្លៃថ្លា និងអារ្យធម៌អង្គរដ៏បវរ កសាងប្រទេសជាតិឲ្យទៅជា "កោះសន្តិភាព" ឡើងវិញ ផ្អែកលើប្រព័ន្ធប្រជាធិបតេយ្យសេរីពហុបក្ស ធានាសិទ្ធិមនុស្ស គោរពច្បាប់, ទទួលខុសត្រូវខ្ពស់ចំពោះវាសនាអនាគតជាតិ ឱយបានឈានឡើងរីកចំរើន លូតលាស់សម្បូររុងរឿងជានិច្ចនិរន្តរ៍។

# (២) ការការបន្សាំបន្សីគ្នារវាងគុណតម្លៃទំនើប និងគុណតម្លៃប្រពៃណីខ្មែរ

- រដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ ជា**រដ្ឋធម្មនុញ្ញមានលក្ខណៈប្រជាធិបតេយ្យជឿនលឿន** ដែលបានកើតចេញពី**ឆន្ទៈរួមរបស់ប្រជារាស្ត្រខ្មែរ**គ្រប់និន្នាការនយោបាយ។ សភាធម្មនុញ្ញបានតាក់តែងរក្សាឱ្យមានមកវិញនូវ**គុណតម្លៃប្រពៃណីខ្មែរ** (គឺ**ជាតិ សាសនា ព្រះមហាក្សត្រ**) អមជាមួយ**គុណតម្លៃធម្មនុញ្ញទំនើប**ជាមូលដ្ឋានគ្រឹះ (គឺ**ប្រជាធិបតេយ្យ សិទ្ធិមនុស្ស នីតិរដ្ឋ**) ដោយតាក់តែងបញ្ចូលទាំងស្រុងនិងដោយលម្អិតនូវខ្លឹមសារនៃ**ឧបសម្ព័ន្ធទី៥ នៃកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីស**ស្តីពី "**គោលការណ៍នៃរដ្ឋធម្មនុញ្ញថ្មីរបស់កម្ពុជា**"។ ក្នុងដំណើរការអនុវត្តជាក់ស្តែង **ការបន្សាំបន្សីគ្នានៃគុណតម្លៃទាំងពីរ** បានបង្កនូវ**កម្លាំងសម្របសម្រួលនិងជំរុញរួមគ្នា** ក្នុងការដោះស្រាយបញ្ហានយោបាយនិងបញ្ហាច្បាប់ ដែលបានកើតមានឡើងជាបន្តបន្ទាប់ ដោយរក្សាបាន**នូវភាពសុខដុមរមនាក្នុងសង្គម (Pragmatisme)** ញ៉ាំងឱ្យរដ្ឋធម្មនុញ្ញនេះ និងរបបនយោបាយមានស្ថិរភាពរយៈពេលវែង ៣០ឆ្នាំ (ពីឆ្នាំ១៩៩៣ ដល់ឆ្នាំ២០២៣)។

# (៣) គុណតម្លៃធម្មនុញ្ញទំនើប

## ▫ ប្រជាធិបតេយ្យ ៖

- សូមមើលមាត្រា១, មាត្រា៣៤ថ្មី(មួយ), មាត្រា៥០, មាត្រា៥១ថ្មី, មាត្រា៧៦ថ្មី, មាត្រា៩៩ថ្មី នៃរដ្ឋធម្មនុញ្ញ

## ▫ សិទ្ធិ ៖

- សូមមើលជំពូកទី៣ នៃរដ្ឋធម្មនុញ្ញ អំពីសិទ្ធិ និងករណីយកិច្ចរបស់ប្រជាពលរដ្ឋខ្មែរ

## ▫ នីតិរដ្ឋ ៖

- សូមមើលមាត្រា៣៨, មាត្រា៣៩, មាត្រា៤៩ថ្មី, មាត្រា១៣៦ថ្មី, មាត្រា១៥២ថ្មី នៃរដ្ឋធម្មនុញ្ញ

# (៤) គុណតម្លៃប្រពៃណីខ្មែរ

## ជាតិ ៖

- សូមមើលជំពូកទី១ អំពីអធិបតេយ្យ, មាត្រា៤៧ និងមាត្រា៦៩ នៃរដ្ឋធម្មនុញ្ញ

## សាសនា ៖

- សូមមើលមាត្រា៤៣, មាត្រា៦៨ នៃរដ្ឋធម្មនុញ្ញ

## ព្រះមហាក្សត្រ ៖

- សូមមើលជំពូកទី២ អំពីព្រះមហាក្សត្រ, មាត្រា១៣២ថ្មី (១១៣ចាស់), មាត្រា១៤៣ថ្មី (១២៤ចាស់) នៃរដ្ឋធម្មនុញ្ញ

# (៥) ការសិក្សាប្រៀបធៀប គុណតម្លៃទំនើប និងគុណតម្លៃបុរាណ

- ការបន្សាំបន្សុំគ្នាត្រូវធ្វើតាមរយៈការសិក្សាប្រៀបធៀបគុណតម្លៃទាំងពីរ។ ដើម្បីគោលដៅនេះ គេត្រូវធ្វើការស្រាវជ្រាវរកជាតុផ្សំនៃគុណតម្លៃទាំងពីរ ដើម្បីយកមកធ្វើការប្រៀបធៀបគ្នា ដោយរកឃើញចំណុចស្របគ្នា និងមិនស្របគ្នា។ នេះជាវិធីសាស្ត្រល្អមួយរួមចំណែកអាចធ្វើឱ្យការយល់ដឹង និងការទទួលយកគុណតម្លៃទំនើបកាន់តែមានប្រសិទ្ធភាព។

# (៦) ពិសោធន៍នៃការធ្វើទំនើបកម្ម ផ្សារភ្ជាប់នឹងគុណតម្លៃឈើ



- ការទាក់ទងនឹងពិសោធន៍នៃការធ្វើទំនើបកម្មរបស់បណ្ដាប្រទេសមិនទាន់រីកចម្រើន ពិសេសប្រទេសនៅអាស៊ី ដែលទទួលយក និងអនុវត្តតាមគំរូនយោបាយអភិវឌ្ឍរបស់បស្ចិមប្រទេស ជាការសង្កេតទូទៅប្រទេសទាំងនោះតែងមានការបម្រុងទុកមួយគឺ "**ទទួលយកនយោបាយទំនើប តែមិនឱ្យបាត់ប្រពៃណីទំនៀមទម្លាប់បុរាណ**" ដែលជាព្រលឹងជាតិរបស់គេ។ ប្រទេសទាំងនោះមានជំហរដូចនេះ អាស្រ័យដោយប្រទេសគេក៏មិនខុសពីកម្ពុជាផងដែរ គឺយើងមានអារ្យធម៌បុរាណដែលជា **មោទនភាពជាតិ**។

# (៧) គុណតម្លៃនៃអត្តសញ្ញាណជាតិ ផ្សារភ្ជាប់ជាមួយលទ្ធិប្រជាធិបតេយ្យ

សម្រាប់ករណីនៃប្រទេសកម្ពុជា គួរមានការសិក្សានិងបង្កលក្ខណៈធ្វើឱ្យប្រជាពលរដ្ឋមានការយល់ដឹងអំពីបេតិកភណ្ឌវប្បធម៌បុរាណរបស់ជាតិ និងមើលឃើញខ្លឹមសារនៃវប្បធម៌នេះក៏មានអត្ថន័យផ្សារភ្ជាប់នឹងគោលការណ៍នៃលទ្ធិប្រជាធិបតេយ្យសេរី ដែលជាកត្តារួមចំណែកពង្រឹងលទ្ធិប្រជាធិបតេយ្យសេរីនៅកម្ពុជា។ ក្នុងគោលដៅនេះ យើងត្រូវធ្វើការសិក្សាអំពីតួនាទីនៃគុណតម្លៃបុរាណក្នុងអភិក្រមបន្សាំបន្សុីគ្នា។

# (៨) ប្រវត្តិសាស្ត្ររុងរឿងនៃសម័យអង្គរ (សវ.ទី៩ ដល់សវ.ទី១៥)



- យោងសម័យហ្វូណន
- ព្រះបាទជ័យវរ្ម័នទី២ (៨០២-៨៥០) **រំដោះប្រទេសពីការត្រួតត្រារបស់ជ្វា** បង្រួបបង្រួមជាតិឡើងវិញ**ចាប់ផ្ដើមកសាងរាជាណាចក្រមួយដ៏ធំ** គឺរាជាណាចក្រអង្គរហើយបាននាំមកនូវ**ប្រព័ន្ធគ្រប់គ្រងមួយ ហៅថា ទេវរាជ**។
- ព្រះបាទសុរិយាវរ្ម័នទី២ (១១១៣-១១៥០) ជាក្សត្រអង្គមួយអង្គដ៏ខ្លាំងពូកែ ដែលបាន**កសាងប្រាសាទអង្គរវត្តដ៏ធំជាងគេនៅលើពិភពលោកឧទ្ទិសដល់ព្រះវិស្ណុ** ប្រាសាទបេងមាលា ព្រមទាំងបានសាងសង់បង្ហើយប្រាសាទវត្តភូ ប្រាសាទព្រះវិហារ។
- ព្រះបាទជ័យវរ្ម័នទី៧ (១១៨១-១២១៨) ត្រូវបានចាត់ទុកជាស្ដេចខ្មែរមួយអង្គដ៏ខ្លាំងក្លានៅក្នុងប្រវត្តិសាស្ត្រខ្មែរ ព្រះអង្គបាន**រំដោះប្រទេសពីការឈ្លានពានពីសំណាក់នគរចម្ប៉ា** និងបាន**ពង្រីកទឹកដីប្រទេសកម្ពុជាឱ្យក្លាយទៅជាចក្រភពខ្មែរ**។ ព្រះអង្គបាន**កសាង អង្គរធំ ប្រាសាទបាយ័នដ៏ល្បីល្បាញ** និង**លើកតម្កើងព្រះពុទ្ធសាសនាមហាយាន**។ ព្រះអង្គក៏ជាស្ដេចដែលបាន**កសាងប្រទេស ប្រកបដោយទឹកចិត្តមនុស្សធម៌**។
- ព្រះបាទសម្ដេចព្រះ **នរោត្តម សីហនុ**
- សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន**

# (៩) ប្រវត្តិសាស្ត្រនៃការធ្លាក់ចុះដុនដាប

ប្រវត្តិសាស្ត្ររបស់ប្រទេសកម្ពុជាចាប់ពីសតវត្សរ៍ទី១៧ រហូតមកដល់វត្តមានរបស់បារាំងនៅឆ្នាំ១៨៦៣ បានបង្ហាញនូវគ្រោះថ្នាក់ដ៏ធំចំពោះប្រទេសជាតិ ដោយកម្ពុជាបានក្លាយជាកម្មវត្ថុនៃការប្រទាញប្រទង់ដើម្បីត្រួតត្រាពីប្រទេសជិតខាងទាំងពីរ គឺសៀម និងវៀតណាម ដែលធ្វើឱ្យការគ្រប់គ្រងប្រទេសធានាសឹងតែពុំបាននូវ **អធិបតេយ្យជាតិ** និង**អត្តសញ្ញាណជាតិ** ។

យោងតាមស្មារតីនៃបុព្វកថានៃរដ្ឋធម្មនុញ្ញ ក្នុងអំឡុងពីរទសវត្សរ៍ចុងក្រោយនៃសង្គ្រាមស៊ីវិល និងរបបគ្រប់គ្រងដ៏មហន្តរាយនៃរបបខ្មែរក្រហម កម្ពុជាបានបាត់បង់អ្វីៗទាំងអស់ រាប់ទាំង **ព្រលឹងជាតិ**។

ការចងចាំនូវប្រវត្តិនៃការធ្លាក់ចុះដុនដាបរបស់ប្រទេសជាតិ ដែលជា**ករណីយកិច្ចរួមនៃការចងចាំ** ដែលត្រូវជៀសវាងកុំឱ្យកើតមានកត្តាអន្តរាយទាំងឡាយតទៅអនាគត។

# ( ១០ ) ព្រះពុទ្ធសាសនា



គឺជាសាសនាធំជាងគេនៅប្រទេសកម្ពុជាដែលប្រជាពលរដ្ឋខ្មែរគោរពប្រតិបត្តិតាម និងមានឥទ្ធិពលជ្រាលជ្រៅលើវប្បធម៌ ជីវភាពរស់នៅរបស់បុគ្គល និងជីវភាពសង្គម។ ព្រះពុទ្ធសាសនា គឺជាសាសនាផង និងជាទស្សនវិជ្ជាផង ចាត់ទុកជាឃ្លាំងចំណេះដឹងដែលជាការប្រៀនប្រដៅរបស់ព្រះពុទ្ធពាក់ព័ន្ធនឹងគ្រប់បញ្ហានៃជីវិតមនុស្សនៅក្នុងសង្គម ដូចជា គុណតម្លៃទាក់ទងនឹងសច្ចធម៌ សីលធម៌ (សីល=ការគោរពសិទ្ធិមនុស្ស) សមធម៌ (ព្រះពុទ្ធបដិសេធទស្សនវណ្ណៈ) ចរិយាធម៌ ព្រហ្មវិហារធម៌ យុត្តិធម៌ សប្បុរសធម៌ កតវេទិតាធម៌ អហិង្សា សន្តិភាព...។ល។

# (១១) ភាពធន់ខាងស្មារតីរបស់ជាតិ

យោងតាមការវាយតម្លៃរបស់បរទេស គេមើលឃើញជនជាតិខ្មែរមានភាពធនខាងស្មារតីខ្ពស់ អាស្រ័យដោយការចាប់ផ្តើមកសាងប្រទេសឡើងវិញចាប់ពី លេខសូន្យ Le Cambodge, année zero (François Ponchaud) តែសម្រេចបានជោគជ័យដ៏ធំធេងក្នុងកិច្ចការពារ និងកសាងប្រទេសបានរីកចម្រើនដូចសព្វថ្ងៃ និងកំពុងបោះជំហានបន្តទៅមុខយ៉ាងស្វាហាប់។

# (១២) កត្តាសុខដុមនីយកម្មសង្គម

- តួនាទីស្នូលនៃគ្រួសារ (ភាពរឹងមាំនៃចំណងគ្រួសារតជំនាន់)
- សាមគ្គីភាពសហគមន៍ (ការជួយគ្នាទៅវិញទៅមក)
- ប្រពៃណីគោរពចាស់ទុំ គោរពអាជ្ញាធរ នាហ្មឺនមុខមន្ត្រី
- និន្នាការសម្របសម្រួលរវាងគូទំនាស់ ចៀសវាងទំនាស់ទាស់ទែង

# (១៣) កត្តាឥទ្ធិពលនៃជំនឿផ្សេងៗ

នៅពេលព្រះពុទ្ធសាសនាបានចាក់ឫសរីកដុះដាលគ្របដណ្តប់សង្គមខ្មែរហើយ ជំនឿដូនតា ព្រលឹងនិយម (Animisme) និងជំនឿព្រហ្មញ្ញសាសនា ក៏នៅបន្តរស់រានមានជីវិតក្រោមដំបូលព្រះពុទ្ធសាសនា។

(យោង ៖ ជំនឿព្រលឹងនិយម គឺខ្មែរជឿលើអារុក្ខ អារក្ស អ្នកតា ពិធីបួងសួង សែនព្រេន សុំសេចក្តីសុខ...)

# (១៤) អនុសាសន៍

-តាមរបៀបសម្របសម្រួល និងរបៀបជ្រើសរើសធាតុផ្សំនៃគុណតម្លៃទាំងពីរ ដើម្បីបន្សាំបន្សុំជាមួយគ្នា។

-ការអនុវត្តការបន្សាំបន្សុំគុណតម្លៃទាំងពីរ ទទួលបានលទ្ធផលជោគជ័យ និងប្រកបដោយចីរភាព ចំណុះនឹងការបកស្រាយខ្លឹមសារនៃគុណតម្លៃនិងការអនុវត្ត ដែលត្រូវធ្វើក្នុងស្មារតីទទួលខុសត្រូវខ្ពស់ ចំពោះឧត្តមប្រយោជន៍ជាតិ។

-ការអនុវត្តការបន្សាំបន្សុំនេះ ក្នុងករណីខ្លះមានការចាំបាច់ត្រូវធ្វើការកែទម្រង់ និងក៏អាចប្រឈមនឹងការប្រឆាំងជំទាស់ ដែលត្រូវដោះស្រាយដោយអត់ធ្មត់បំផុត។

# (១៥) ព្រឹត្តិការណ៍ប្រវត្តិសាស្ត្រពាក់ព័ន្ធ

- **ថ្ងៃទី០២ ធ្នូ ១៩៨៧ ៖** ចាប់ផ្ដើមពីការចរចា " **សីហនុ-ហ៊ុន សែន** " នៅហ្វែរអង់តាដឺណ័រ ប្រទេសបារាំង និងការចរចាជាបន្តបន្ទាប់
- **ថ្ងៃទី២៣ តុលា ១៩៩១ ៖** កិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីស ស្ដីពីដំណោះស្រាយនយោបាយរួមបញ្ហាកម្ពុជា
- **ថ្ងៃទី២៣-២៨ ឧសភា ១៩៩៣ ៖** ការបោះឆ្នោតជ្រើសតាំងសភាធម្មនុញ្ញ ដើម្បីតាក់តែងសេចក្ដីព្រាងរដ្ឋធម្មនុញ្ញថ្មីរបស់កម្ពុជា
- **ថ្ងៃទី២១ កញ្ញា ១៩៩៣ ៖** រដ្ឋធម្មនុញ្ញថ្មីត្រូវបានអនុម័តដោយសភាធម្មនុញ្ញ
- **ថ្ងៃទី២៤ កញ្ញា ១៩៩៣ ៖** រដ្ឋធម្មនុញ្ញត្រូវបានប្រកាសឱ្យប្រើ ទន្ទឹមនឹងនេះសភាធម្មនុញ្ញក្លាយជារដ្ឋសភាជាតិ

# (១៦) លទ្ធផលនៃការបោះឆ្នោតជ្រើសតាំងសភាជាតិ



- គណបក្សនយោបាយចូលរួមការបោះឆ្នោតចំនួន ២០ គណបក្ស
- ប្រជាពលរដ្ឋដែលមានឈ្មោះក្នុងបញ្ជីបោះឆ្នោតចំនួន ៤.៧៦៤.៤៣០នាក់
- ប្រជាពលរដ្ឋដែលបានទៅចូលរួមការបោះឆ្នោតចំនួន ៤.២៦៧.១៩២នាក់ ស្មើនឹង ៨៩,៥៦%
- គណបក្សនយោបាយជាប់ឆ្នោតទទួលបានអាសនៈ ៖

១. គណបក្សហ៊្វុនស៊ិនប៉ិច ៥៨អាសនៈ

២. គណបក្សប្រជាជនកម្ពុជា ៥១អាសនៈ

៣. គណបក្សសេរីនិយមព្រះពុទ្ធសាសនា ១០អាសនៈ

៤. គណបក្សម៉ូលីណាកា ០១អាសនៈ

# (១៧) រដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ ជារដ្ឋធម្មនុញ្ញទី៦

•ប្រទេសកម្ពុជាចាប់តាំងពីឆ្នាំ១៩៤៧ មកដល់បច្ចុប្បន្នមានរដ្ឋធម្មនុញ្ញចំនួនប្រាំមួយ ដែលត្រូវបានអនុម័តសម្រាប់ដំណើរការនៃការគ្រប់គ្រងរដ្ឋ។ រដ្ឋធម្មនុញ្ញទាំងនោះរួមមាន ៖

**១-រដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៤៧ ៖** ជារដ្ឋធម្មនុញ្ញទី១នៃប្រទេសកម្ពុជា ដែលគេហៅថារដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាទី១ ដែលត្រូវបានរៀបចំតាក់តែងឡើងដោយគណបក្សប្រជាធិបតេយ្យ ដែលដឹកនាំដោយព្រះអង្គម្ចាស់ **ស៊ីសុវត្ថិ យុត្តិវង្ស** ជាគណបក្សនយោបាយដែលបានឈ្នះដាច់គេនៅក្នុងការបោះឆ្នោតនាឆ្នាំ១៩៤៦ ដើម្បីជ្រើសតាំងសភាធម្មនុញ្ញលើកទី១ ក្នុងប្រវត្តិសាស្ត្រនៃប្រទេសកម្ពុជា តាមគោលការណ៍នៃលទ្ធិប្រជាធិបតេយ្យ។ រដ្ឋធម្មនុញ្ញនេះត្រូវបានព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះចៅក្រុងកម្ពុជា ទ្រង់ប្រោសព្រះរាជទានដល់ប្រជារាស្ត្រខ្មែរនៅថ្ងៃទី០៦ ខែឧសភា ឆ្នាំ១៩៤៧ (***រដ្ឋធម្មនុញ្ញនេះមានទាំងអស់ ១០ជំពូកនិង១០៧មាត្រា***)។ ថ្ងៃដែលព្រះមហាក្សត្រឡាយព្រះហស្តលេខាប្រកាសឱ្យប្រើរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៤៧ ត្រូវបានចាត់ទុកជាថ្ងៃនៃទិវាបុណ្យជាតិដ៏សំខាន់នាពេលនោះ។ រដ្ឋធម្មនុញ្ញឆ្នាំ១៩៤៧ បានទទួលការកែប្រែជាបន្តបន្ទាប់រហូតមកដល់ថ្ងៃទី៣១ ខែមីនា ឆ្នាំ១៩៦៤ ធ្វើឱ្យរដ្ឋធម្មនុញ្ញនេះមានទាំងអស់ ១២ជំពូកនិង១២២មាត្រា។

# (១៧) រដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ ជារដ្ឋធម្មនុញ្ញទី៦ (ត)

**២-រដ្ឋធម្មនុញ្ញសាធារណរដ្ឋខ្មែរឆ្នាំ១៩៧២ ៖** ជារដ្ឋធម្មនុញ្ញទី២ ដែលផ្លាស់ប្តូរ របបរាជានិយមអាស្រ័យរដ្ឋធម្មនុញ្ញ ទៅជារបបសាធារណរដ្ឋ (ប្រធានាធិបតីនិយម) វិញ ក្រោយពេលដែលលោកសេនាប្រមុខ **លន់ នល់** ធ្វើរដ្ឋប្រហារទម្លាក់ **ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ** ចេញពីព្រះប្រមុខរដ្ឋ នាថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០។ រដ្ឋធម្មនុញ្ញសាធារណរដ្ឋខ្មែរត្រូវបានប្រជារាស្ត្រខ្មែរទទួលយល់ព្រមដោយប្រជាមតិ នាថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៧២ ហើយត្រូវបានប្រកាសឱ្យប្រើនៅថ្ងៃទី១០ ខែឧសភា ឆ្នាំ១៩៧២ និងចូលជាធរមាននៅថ្ងៃទី១២ ខែឧសភា ឆ្នាំ១៩៧២។ រដ្ឋធម្មនុញ្ញនេះមានទាំងអស់ ១១ជំពូកនិង១២១មាត្រា។

# (១៧) រដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ ជារដ្ឋធម្មនុញ្ញទី៦ (ត)

**៣-រដ្ឋធម្មនុញ្ញកម្ពុជាប្រជាធិបតេយ្យឆ្នាំ១៩៧៦ ៖** ត្រូវបានបង្កើតឡើងតាមរយៈមហាសន្និបាតជាតិលើកទី៣ ដែលបានប្រារព្ធធ្វើឡើងនៅថ្ងៃទី២៥ ដល់ថ្ងៃទី២៧ ខែមេសា ឆ្នាំ១៩៧៥ និងបានធ្វើអនុមតិនៅថ្ងៃទី១៤ ខែធ្នូ ឆ្នាំ១៩៧៥ ហើយបានអនុម័តដោយសភាជាតិ ដែលមានសមាជិកចំនួន ១០០០នាក់នៅទីក្រុងភ្នំពេញ និងត្រូវបានប្រកាសឱ្យប្រើជាផ្លូវការនៅថ្ងៃទី០៥ ខែមករា ឆ្នាំ១៩៧៦។ រដ្ឋធម្មនុញ្ញនេះមានទាំងអស់ ១៦ជំពូកនិង២១មាត្រា។ ប្រទេសកម្ពុជាត្រូវបានប្តូរឈ្មោះជាផ្លូវការថា "**កម្ពុជាប្រជាធិបតេយ្យ**"។

# (១៧) រដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ ជារដ្ឋធម្មនុញ្ញទី៦ (ត)

**៤-រដ្ឋធម្មនុញ្ញសាធារណរដ្ឋប្រជាមានិតកម្ពុជាឆ្នាំ១៩៨១ ៖** បន្ទាប់ពីកងទ័ពរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជាបានវាយផ្តួលរំលំរបបប្រល័យពូជសាសន៍ខ្មែរក្រហមជាស្ថាពរ នាថ្ងៃទី០៧ ខែមករា ឆ្នាំ១៩៧៩ ហើយបានចូលកាន់កាប់រដ្ឋធានីភ្នំពេញ និងបានប្រកាសឈ្មោះផ្លូវការថ្មីនៃប្រទេសកម្ពុជាគឺ "សាធារណរដ្ឋប្រជាមានិតកម្ពុជា"។ រដ្ឋធម្មនុញ្ញថ្មីមួយត្រូវបានបង្កើតឡើងដោយរដ្ឋសភានៃសាធារណរដ្ឋប្រជាមានិតកម្ពុជា ដែលបានអនុម័តជាឯកច្ឆ័ននៅថ្ងៃទី២៥ ខែមិថុនា ឆ្នាំ១៩៨១ និងប្រកាសឱ្យប្រើជាផ្លូវការនៅថ្ងៃទី២៧ ខែមិថុនា ឆ្នាំ១៩៨១។ រដ្ឋធម្មនុញ្ញនេះមានទាំងអស់ ១០ជំពូក និង៩៣មាត្រា។

# (១៧) រដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ ជារដ្ឋធម្មនុញ្ញទី៦ (ត)



**៥-រដ្ឋធម្មនុញ្ញរដ្ឋកម្ពុជាឆ្នាំ១៩៨៩ ៖** រដ្ឋសភានៃសាធារណរដ្ឋប្រជាមានិតកម្ពុជា បានបើកសម័យប្រជុំដើម្បីពិនិត្យនិងអនុម័តលើសំណើកែប្រែរដ្ឋធម្មនុញ្ញ ដោយធ្វើការផ្លាស់ប្តូរនិងកែប្រែនូវមាត្រាមួយចំនួន ដើម្បីតម្រូវតាមស្ថានការណ៍របស់ប្រទេសជាតិ។ ដូច្នេះ រដ្ឋធម្មនុញ្ញនៃរដ្ឋកម្ពុជា ត្រូវបានរដ្ឋសភានៃសាធារណរដ្ឋប្រជាមានិតកម្ពុជាអនុម័តជាឯកច្ឆ័ន្ទ នាសម័យប្រជុំវិសាមញ្ញនៃនីតិកាលទី១ នៅថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៨៩។ រដ្ឋធម្មនុញ្ញនេះមានទាំងអស់ ១០ជំពូកនិង៩៣មាត្រា។

# (១៧) រដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ ជារដ្ឋធម្មនុញ្ញទី៦ (តចប់)

**៦-រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣ ៖** ក្រោយកិច្ចព្រមព្រៀងទីក្រុងប៉ារីសថ្ងៃទី២៣ ខែតុលា ឆ្នាំ១៩៩១ ការបោះឆ្នោតមួយត្រូវបានរៀបចំឡើងដោយអាជ្ញាធរបណ្ដោះអាសន្ននៃអង្គការសហប្រជាជាតិប្រចាំនៅកម្ពុជា ហៅកាត់ថា អ៊ុនតាក់ (UNTAC) ហើយរដ្ឋធម្មនុញ្ញថ្មីមួយក៏ត្រូវបានអនុម័តនៅថ្ងៃទី២១ ខែកញ្ញា ឆ្នាំ១៩៩៣ និងប្រកាសឱ្យប្រើដោយព្រះរាជក្រមចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ១៩៩៣ (រដ្ឋធម្មនុញ្ញនេះមានទាំងអស់ ១៤ជំពូកនិង១៣៩មាត្រា)។ បច្ចុប្បន្នរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ គឺបានធ្វើវិសោធនកម្មចំនួន ១១លើក ធ្វើឱ្យរដ្ឋធម្មនុញ្ញនេះមានទាំងអស់ ១៧ជំពូកនិង១៦០មាត្រា។

# (១៨) រដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ មានលក្ខណៈជឿនលឿន

## ឧបសម្ព័ន្ធទី៥ នៃកិច្ចព្រមព្រៀងទីក្រុងប៉ារីស

## បណ្តាគោលការណ៍សម្រាប់រដ្ឋធម្មនុញ្ញថ្មីមួយរបស់កម្ពុជា

១- រដ្ឋធម្មនុញ្ញ គឺជាច្បាប់កំពូលរបស់ប្រទេស។ គេអាចធ្វើការកែប្រែរដ្ឋធម្មនុញ្ញ នេះបាន លុះត្រាតែមានរបៀបរបបចាត់តាំងមួយទាក់ទងដល់ការយល់ព្រមពីអង្គការនីតិបញ្ញត្តិ ការធ្វើប្រជាមតិ ឬក៏ដោយវិធីទាំងពីរនេះតែម្តង។

២- ប្រវត្តិសាស្ត្រថ្មីៗប្រកបដោយសោកនាដកម្មនៅកម្ពុជា ទាមទារឱ្យមានវិធានការពិសេស ដើម្បីធានាការការពារសិទ្ធិមនុស្ស។ ហេតុដូច្នេះរដ្ឋធម្មនុញ្ញ ត្រូវរួមមានសេចក្តីថ្លែងការណ៍មួយអំពីសិទ្ធិជាមូលដ្ឋាន នៅក្នុងនោះមានសិទ្ធិក្នុងការមានជីវិតរស់នៅ សេរីភាពរបស់បុគ្គល សន្តិសុខ សេរីភាពក្នុងការធ្វើដំណើរ សេរីភាពក្នុងជំនឿសាសនា រួមប្រជុំគ្នានិងបង្កើតសមាគម រួមមានគណបក្សនយោបាយ និងសហជីព ដំណើរការតុលាការត្រឹមត្រូវនិងភាពស្មើគ្នាចំពោះមុខច្បាប់ ការការពារ

# (១៨) រដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ មានលក្ខណៈជឿនលឿន (ត)

កុំឱ្យមានការដកហូតកម្មសិទ្ធិដោយវិធីផ្តាច់ការ ឬការដកហូតកម្មសិទ្ធិឯកជនដោយគ្មានការសង ជំងឺចិត្តដ៏ត្រឹមត្រូវ និងសេរីភាពដោយគ្មានការប្រកាន់រើសអើងពូជសាសន៍ ជនជាតិ ជំនឿ សាសនា ឬភេទឡើយ។ រដ្ឋធម្មនុញ្ញត្រូវហាមឃាត់នូវការអនុវត្តន៍ច្បាប់ឧក្រិដ្ឋទៅលើឧក្រិដ្ឋកម្ម ដែលកើតឡើងក្នុងអតីតកាល។ សេចក្តីប្រកាសត្រូវសមស្របទៅនឹងប្រការទាំងឡាយនៃសេចក្តីប្រកាសជាសកលអំពីសិទ្ធិមនុស្ស ព្រមទាំងកិច្ចព្រមព្រៀងអន្តរជាតិដ៏ទៃទៀតដែលពាក់ព័ន្ធ។ បុគ្គលដែលត្រូវរំលោភបំពានមានសិទ្ធិប្តឹងទៅតុលាការដើម្បីកាត់សេចក្តី និងធ្វើឱ្យគេគោរពសិទ្ធិទាំងអស់នេះ។

៣- រដ្ឋធម្មនុញ្ញត្រូវប្រកាសអំពីលក្ខន្តិកៈប្រទេសកម្ពុជា ជារដ្ឋអធិបតេយ្យ ឯករាជ្យ និងអព្យាក្រឹតមួយ និងអំពីឯកភាពជាតិរបស់ប្រជាជនកម្ពុជា។

# (១៨) រដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ មានលក្ខណៈជឿនលឿន (ត)



៤- រដ្ឋធម្មនុញ្ញត្រូវប្រកាសថា កម្ពុជានឹងអនុវត្តប្រព័ន្ធប្រជាធិបតេយ្យសេរី ដោយឈរលើមូលដ្ឋានពហុបក្ស។ រដ្ឋធម្មនុញ្ញត្រូវកំណត់ឱ្យមានការបោះឆ្នោតដ៏ត្រឹមត្រូវ និងតាមកាលវេលា។ រដ្ឋធម្មនុញ្ញត្រូវអនុញ្ញាតសិទ្ធិសម្រាប់បោះឆ្នោត និងឈរឈ្មោះឱ្យគេបោះឆ្នោតតាមរបៀបបោះឆ្នោតដោយសកល និងស្មើភាព។ រដ្ឋធម្មនុញ្ញត្រូវអនុញ្ញាតឱ្យមានការបោះឆ្នោតដោយសម្ងាត់ ដោយតម្រូវឱ្យទំរង់បែបបទនៃការបោះឆ្នោតត្រូវផ្តល់ឱកាសគ្រប់ គ្រាន់ និងសមរម្យ ដើម្បីរៀបចំ និងចូលរួមក្នុងដំណើរការបោះឆ្នោត។

# (១៨) រដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ មានលក្ខណៈជឿនលឿន (តចប់)

៥- ត្រូវបង្កើតអង្គការតុលាការមួយឯករាជ្យ ដែលត្រូវមានអំណាចដាក់ឱ្យ អនុវត្តនូវបណ្តាសិទ្ធិដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ។

៦- រដ្ឋធម្មនុញ្ញត្រូវអនុម័តដោយសំឡេងភាគច្រើនពីរភាគបីនៃសមាជិករបស់សភាធម្មនុញ្ញ។

# (១៩) វិសោធនកម្មរដ្ឋធម្មនុញ្ញធ្វើឡើងស្របតាមនីតិវិធីកំណត់ក្នុងរដ្ឋធម្មនុញ្ញ



- អនុលោមតាមមាត្រាមួយចំនួននៃរដ្ឋធម្មនុញ្ញ ៖ សុំមើលមាត្រា១៥៣ថ្មី (ពីរ មាត្រា១៥១ថ្មី), មាត្រា១៥៤ថ្មី (ពីរ មាត្រា១៥២ថ្មី), មាត្រា១៥៥ថ្មី (ពីរ មាត្រា១៥៣ថ្មី) វិសោធនកម្មរដ្ឋធម្មនុញ្ញអាចធ្វើទៅបាន លុះត្រាតែការធ្វើនោះ**ស្របតាមបរិបទនៃសភាពការណ៍ជាក់ស្តែង មិនត្រូវប៉ះពាល់ដល់ប្រព័ន្ធប្រជាធិបតេយ្យសេរីពហុបក្សនិងរបបរាជានិយមអាស្រ័យដោយរដ្ឋធម្មនុញ្ញ** និងនៅពេល**ប្រទេសជាតិមិនឋិតក្នុងភាពអាសន្ន**។
- បញ្ញត្តិហាមមិនអាចសុំកែប្រែជាដាច់ខាត គឺ**វាក្យខ័ណ្ឌទីមួយនៃមាត្រា៧ នៃរដ្ឋធម្មនុញ្ញ** (**កំណត់ក្នុងមាត្រា១៧ នៃរដ្ឋធម្មនុញ្ញ**)

# (២០) ការចរចាក្នុងស្មារតីបង្រួបបង្រួមផ្សះផ្សាជាតិ



- មាត្រា៥២ នៃរដ្ឋធម្មនុញ្ញ " រាជរដ្ឋាភិបាលកម្ពុជា ប្តេជ្ញារក្សាការពារឯករាជ្យ អធិបតេយ្យ បូរណភាពទឹកដីនៃព្រះរាជាណាចក្រកម្ពុជា អនុវត្តនយោបាយបង្រួបបង្រួមជាតិ ដើម្បីការពារឯកភាពជាតិ រក្សាការពារទំនៀមទម្លាប់និងប្រពៃណីល្អរបស់ជាតិ។ រាជរដ្ឋាភិបាលកម្ពុជាត្រូវការពារនីត្យានុកូលភាពធានាសណ្តាប់ធ្នាប់ និងសន្តិសុខសាធារណៈ។ រដ្ឋយកចិត្តទុកដាក់ជាអាទិភាព ចំពោះជីវភាពរស់នៅ និងសុខុមាលភាពរបស់ប្រជាពលរដ្ឋ។ "

# (២១) សំឡេងឆ្នោតជាលទ្ធផលនៃការប្រើប្រាស់សិទ្ធិនយោបាយរបស់ប្រជាពលរដ្ឋ

- នៅក្នុងឆ្នាំបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ចាប់តាំងពីឆ្នាំ១៩៩៣ រហូតដល់ឆ្នាំ២០២៣ ជាមធ្យម **អ្នកបានចូលរួមបោះឆ្នោតចំនួន ៨២.៧០%** (នៅឆ្នាំ២០២៣ នីតិកាលទី៧ **អ្នកបានចូលរួមបោះឆ្នោតមានចំនួន ៨៤.៥៨%**)។

# (២២) ច្បាប់ធម្មនុញ្ញបន្ថែម

- ជួយបំបែកភាពទាល់ច្រកផ្នែកនយោបាយនៅកម្ពុជា ដែលបានជាប់គាំងអស់រយៈពេលជិត១ឆ្នាំ និងមានគោលដៅផ្លាស់ប្តូរសំឡេងអនុម័តរបស់រដ្ឋសភាក្នុងការបោះឆ្នោតជ្រើសតាំងក្បាលម៉ាស៊ីននៃរដ្ឋសភា ព្រមទាំងការបោះឆ្នោតផ្តល់សេចក្តីទុកចិត្តដល់រាជរដ្ឋាភិបាល ដោយសម្រុតពី**មតិភាគច្រើនពីរភាគបី (២/៣)** ឱ្យចុះមកត្រឹម**មតិភាគច្រើនដាច់ខាត (៥០%+១)** និងបានលើកកម្ពស់ប្រសិទ្ធភាពការដឹកនាំរបស់ស្ថាប័ននីតិប្បញ្ញត្តិ ស្ថាប័ននីតិប្រតិបត្តិ នៃព្រះរាជាណាចក្រកម្ពុជា ព្រមទាំងបានអភិវឌ្ឍលទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស ឱ្យកាន់តែរីកចម្រើនថែមទៀត។ **ប្រជាធិបតេយ្យកាន់តែរីកចម្រើន សំឡេងអនុម័តនិងកូរ៉ុមកាន់តែថយចុះតិច។**

# (២៣) របបរាជានិយមអាស្រ័យរដ្ឋធម្មនុញ្ញ ក្នុងទម្រង់រាជានិយមជឿនលឿន

- មាត្រា១ វាក្យខ័ណ្ឌទី១ នៃរដ្ឋធម្មនុញ្ញ " **ប្រទេសកម្ពុជា ជាព្រះរាជាណាចក្រដែលព្រះមហាក្សត្រទ្រង់ប្រតិបត្តិតាមរដ្ឋធម្មនុញ្ញនិងតាមលទ្ធិប្រជាធិបតេយ្យ សេរីពហុបក្ស។** "
- មាត្រា៧ វាក្យខ័ណ្ឌទី១ នៃរដ្ឋធម្មនុញ្ញ " **ព្រះមហាក្សត្រកម្ពុជាទ្រង់គ្រងរាជសម្បត្តិ ប៉ុន្តែទ្រង់មិនកាន់អំណាចឡើយ។** "
- មាត្រា១០ វាក្យខ័ណ្ឌទី១ នៃរដ្ឋធម្មនុញ្ញ " **របបរាជានិយមកម្ពុជា ជារបបជ្រើសតាំង។** "

# (២៤) ព្រះមហាក្សត្រជានិមិត្តរូប នៃឯកភាពជាតិ និងនិរន្តរភាពជាតិ

- មាត្រា៨ នៃរដ្ឋធម្មនុញ្ញ " ព្រះមហាក្សត្រព្រះអង្គទ្រង់ជានិមិត្តរូបនៃឯកភាពជាតិ និងនិរន្តរភាពជាតិ។ ព្រះមហាក្សត្រទ្រង់ជាអ្នកធានាឯករាជ្យជាតិ អធិបតេយ្យនិងបូរណភាពទឹកដីនៃព្រះរាជាណាចក្រកម្ពុជា ទ្រង់ជាអ្នកធានាការគោរពសិទ្ធិនិងសេរីភាពរបស់ប្រជាពលរដ្ឋ និងការគោរពសន្ធិសញ្ញាអន្តរជាតិ។ "
- មាត្រា៩ នៃរដ្ឋធម្មនុញ្ញ " ព្រះមហាក្សត្រទ្រង់មានតួនាទីខ្ពង់ខ្ពស់ជាអាជ្ញាកណ្តាល ដើម្បីធានាការប្រព្រឹត្តទៅនៃអំណាចសាធារណៈឱ្យមានភាពទៀងទាត់។ "

# (២៥) ប្រជាពលរដ្ឋខ្មែរជាម្ចាស់វាសនានៃប្រទេសជាតិរបស់ខ្លួន
# (២៦) អំណាចទាំងបីមានសមត្ថកិច្ចដាច់ពីគ្នា



- មាត្រា៥១ថ្មី នៃរដ្ឋធម្មនុញ្ញ " ព្រះរាជាណាចក្រកម្ពុជាអនុវត្តនយោបាយប្រជាធិបតេយ្យសេរីពហុបក្ស។ ប្រជាពលរដ្ឋខ្មែរជាម្ចាស់វាសនានៃប្រទេសជាតិរបស់ខ្លួន។ អំណាចទាំងអស់ជារបស់ប្រជាពលរដ្ឋ។ ប្រជាពលរដ្ឋប្រើអំណាចរបស់ខ្លួនតាមរយៈ រដ្ឋសភា ព្រឹទ្ធសភា រាជរដ្ឋាភិបាល និងសាលាជំរះក្តី។ អំណាចបែងចែកដាច់ពីគ្នារវាងអំណាចនីតិប្បញ្ញត្តិ  អំណាចនីតិប្រតិបត្តិ និងអំណាចតុលាការ។ "

# (២៧) គោលការណ៍អក្សរសាស្ត្រគុណភាព នៃអំណាច



- មាត្រា៧៨ នៃរដ្ឋធម្មនុញ្ញ " **នីតិកាលរបស់រដ្ឋសភាមានកំណត់ ៥ឆ្នាំ ហើយត្រូវផុតកំណត់នៅពេលដែលរដ្ឋសភាថ្មីចូលកាន់តំណែង។ រដ្ឋសភាមិនអាចត្រូវបានរំលាយមុនផុតអាណត្តិបានឡើយ វៀរលែងតែក្នុងករណីដែលរាជរដ្ឋាភិបាលត្រូវបានទម្លាក់ពីរដងក្នុងរយៈ ១២ខែ។ ក្នុងករណីនេះព្រះមហាក្សត្រត្រូវរំលាយរដ្ឋសភា ក្រោយពីព្រះអង្គទ្រង់បានទទួលការស្នើពីនាយករដ្ឋមន្ត្រី និងបន្ទាប់ពីទ្រង់បានការយល់ព្រមពីប្រធានរដ្ឋសភា។ ការបោះឆ្នោតដើម្បីជ្រើសរើសរដ្ឋសភាថ្មី នឹងប្រព្រឹត្តទៅក្នុងរយៈពេល ៦០ថ្ងៃយ៉ាងយូរ ចាប់តាំងពីថ្ងៃរំលាយរដ្ឋសភាមក។ ក្នុងរយៈកាលនេះ រាជរដ្ឋាភិបាលមានតែភារកិច្ចដឹកនាំការងារប្រចាំថ្ងៃតែប៉ុណ្ណោះ។ ក្នុងពេលមានសង្គ្រាម ឬក្នុងកាលៈទេសៈពិសេសដទៃទៀតដែលមិនអាចធ្វើការបោះឆ្នោតកើត រដ្ឋសភាអាចប្រកាសបន្តនីតិកាលរបស់ខ្លួនមួយដងបានមួយឆ្នាំ តាមសំណើរបស់ព្រះមហាក្សត្រ។ ការប្រកាសបន្តនីតិកាលរបស់រដ្ឋសភាត្រូវសំរេចដោយមតិយល់ព្រមពីរភាគបីយ៉ាងតិចនៃចំនួនសមាជិករដ្ឋសភាទាំងមូល។** "

# (២៨) កម្ពុជាប្រតិបត្តិរបបបោះឆ្នោតពហុបក្សយ៉ាងទៀងទាត់

- គណបក្សចូលរួមបោះឆ្នោតតាមនីតិកាលនីមួយៗ ៖
  - នីតិកាលទី១ (១៩៩៣) ៖ ២០គណបក្ស
  - នីតិកាលទី២ (១៩៩៨) ៖ ៣៩គណបក្ស
  - នីតិកាលទី៣ (២០០៣) ៖ ២៣គណបក្ស
  - នីតិកាលទី៤ (២០០៨) ៖ ១១គណបក្ស
  - នីតិកាលទី៥ (២០១៣) ៖ ០៨គណបក្ស
  - នីតិកាលទី៦ (២០១៨) ៖ ២០គណបក្ស
  - នីតិកាលទី៧ (២០២៣) ៖ ១៨គណបក្ស

# (២៩) វិសោធនកម្មរដ្ឋធម្មនុញ្ញលើកទី៦ (ឆ្នាំ២០០៨)

- ជាលទ្ធផលសម្រេចបានមកដល់ពេលនេះ ដំណើរប្រជាធិបតេយ្យនីយកម្មថ្នាក់ក្រោមជាតិបានវិវត្តឈានឡើងពេញលេញ តាមរយៈការរៀបចំរចនាសម្ព័ន្ធនិងប្រព័ន្ធគ្រប់គ្រងរដ្ឋបាល តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។

# (៣០) វិសោធនកម្មរដ្ឋធម្មនុញ្ញលើកទី៥ (ឆ្នាំ២០០៦)

- ភាពទាល់ច្រកផ្នែកនយោបាយត្រូវបានចៀសវាងក្នុង អំឡុងពេលបើកនីតិកាលទីបួន (ឆ្នាំ២០០៨) និងនីតិកាលទីប្រាំ (ឆ្នាំ២០១៣) ព្រោះគណបក្សប្រជាជនកម្ពុជាបានឈ្នះអាសនៈច្រើនជាងពាក់កណ្តាលនៅក្នុងរដ្ឋសភា។ ដូច្នេះ គណបក្សប្រជាជនកម្ពុជាមានលទ្ធភាពបង្កើតរាជរដ្ឋាភិបាលតែម្នាក់ឯងនៅក្នុងសម័យប្រជុំទាំងពីរ។ វិសោធនកម្មនេះត្រូវផ្តល់ប្រយោជន៍ដល់គណបក្សនយោបាយទាំងអស់នាពេលបច្ចុប្បន្ន ក៏ដូចជាទៅថ្ងៃអនាគត ដើម្បីចៀសវាងភាពទាល់ច្រកផ្នែកនយោបាយ ព្រោះគណបក្សនយោបាយទាំងអស់ពិតជាមានការពិបាកធំណាស់ក្នុងការឈ្នះដោយមតិភាគច្រើនប្រាំពីរភាគដប់ (**៨៦អាសនៈ**) នៅក្នុងការបោះឆ្នោតបង្កើតរាជរដ្ឋាភិបាលតែម្នាក់ឯង។

# (៣១) វិសោធនកម្មរដ្ឋធម្មនុញ្ញលើកទី៧ (ឆ្នាំ២០១៤)

- វិសោធនកម្មនេះមានផលវិជ្ជមានទៅលើគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ព្រោះវាបានធ្វើឱ្យមានការទុកចិត្តពីសាធារណជនកាន់តែច្រើនចំពោះស្ថាប័ននេះ។ សមាសភាពគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតដែលត្រូវបានកែប្រែដូចមានចែងនៅក្នុងរដ្ឋធម្មនុញ្ញ ត្រូវបានយល់ព្រមទទួលយកដោយអ្នកនយោបាយ និងសហគមន៍ជាតិនិងអន្តរជាតិផ្សេងទៀត។ វិសោធនកម្មនេះត្រូវបានចាត់ទុកថាជាជំហានមួយទៀតឆ្ពោះទៅធ្វើទំនើបកម្ម និងបទដ្ឋានូបនីយកម្មដំណើរការបោះឆ្នោតនៅប្រទេសកម្ពុជា តាមទិសនៃនីតិរដ្ឋ និងលទ្ធិប្រជាធិបតេយ្យពិតប្រាកដ។

# (៣២) វិសោធនកម្មរដ្ឋធម្មនុញ្ញលើកទី៨ (ឆ្នាំ២០១៨)

- បានកំណត់ដែនបន្ទាត់ក្រហម ទាក់ទងនឹងកាតព្វកិច្ចតម្រូវចំពោះគណបក្សនយោបាយនីមួយៗ ដែលត្រូវគោរពរដ្ឋធម្មនុញ្ញនិងច្បាប់ និងមិនត្រូវធ្វើសកម្មភាពណាមួយ ទោះដោយផ្ទាល់ឬដោយប្រយោលក្តី ដែលនាំឱ្យប៉ះពាល់ដល់ឧត្តមប្រយោជន៍ជាតិ។

# (៣៣) វិសោធនកម្មរដ្ឋធម្មនុញ្ញលើកទី៩ (ឆ្នាំ២០២១)



- រដ្ឋសភា ព្រឹទ្ធសភា រាជរដ្ឋាភិបាល និងក្រុមប្រឹក្សាធម្មនុញ្ញ គឺជាស្ថាប័នកំពូលរបស់ជាតិ និងមានការទទួលខុសត្រូវក្នុងការសម្រេចលើកិច្ចការសំខាន់ៗដែលជាអាយុជីវិតរបស់ប្រទេសជាតិ សំដៅធានាការពារឯករាជ្យជាតិ អធិបតេយ្យជាតិ និងបូរណភាពទឹកដីនៃព្រះរាជាណាចក្រកម្ពុជា ឧត្តមប្រយោជន៍ជាតិនិងប្រជាជនកម្ពុជា និងការប្រឆាំងដាច់ខាតនឹងការជ្រៀតជ្រែកពីបរទេសចូលក្នុងកិច្ចការផ្ទៃក្នុងរបស់ជាតិ ឬការបង្គាប់បញ្ជាចំពោះគោលនយោបាយជាតិនិងអន្តរជាតិរបស់កម្ពុជា។ ផ្អែកលើមូលដ្ឋាននេះ រាជរដ្ឋាភិបាលបានស្នើធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញ សំដៅចារឹកគោលការណ៍គ្រឹះទាំងនេះចូលទៅក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាដែលជាច្បាប់គ្រឹះ និងជាច្បាប់កំពូលរបស់ជាតិ ដោយកំណត់ឱ្យ**ប្រធានរដ្ឋសភា ប្រធានព្រឹទ្ធសភា នាយករដ្ឋមន្ត្រី** និង**ប្រធានក្រុមប្រឹក្សាធម្មនុញ្ញ** ត្រូវតែជាឥស្សរជនដែលមាន " **សញ្ជាតិខ្មែរតែមួយគត់** "។

# (៣៤) វិសោធនកម្មរដ្ឋធម្មនុញ្ញលើកទី១០ (ឆ្នាំ២០២២)

- វិសោធនកម្មនេះមានផលវិជ្ជមានទៅលើស្ថាប័ននីតិប្រតិបត្តិ ពីព្រោះវាបានធានាឱ្យស្ថាប័នកំពូលរបស់ជាតិមួយនេះ ដែលមានបេសកកម្មចម្បងក្នុងការដឹកនាំការងារទូទៅរបស់រដ្ឋ មានដំណើរការប្រព្រឹត្តទៅដោយរលូន និងប្រកបដោយនិរន្តរភាពនៅគ្រប់កាលៈទេសៈ និងធានាការពារថែរក្សាបាននូវសន្តិភាព សន្តិសុខសង្គម សណ្តាប់ធ្នាប់សាធារណៈ និងស្ថិរភាពនយោបាយរបស់ប្រទេសជាតិនៅគ្រប់កាលៈទេសៈ ដើម្បីជាគ្រឹះសម្រាប់ការអភិវឌ្ឍប្រទេសជាតិលើគ្រប់វិស័យ និងសេចក្តីសុខសាន្តរបស់ប្រជារាស្ត្រខ្មែរ។

# (៣៥) សណ្ដាប់ធ្នាប់នយោបាយ

- **គណបក្សធំទាស់មួយចំនួនបានវិវត្តក្លាយជាចលនានយោបាយជ្រុលនិយម** ប្រើការញុះញង់បង្កអស្ថិរភាពសង្គម ធ្វើសកម្មភាពផ្ទុយនឹងច្បាប់ និងមិនស្របតាមគោលការណ៍ប្រជាធិបតេយ្យ ដោយមាននិន្នាការប្រឆាំងដើម្បីផ្ដួលរំលំក្រៅនីតិវិធីនៃការបោះឆ្នោត។

# (៣៦) ឧត្តមភាពនៃរដ្ឋធម្មនុញ្ញ

- មាត្រា១៥២.-ថ្មី (ពីរ មាត្រា១៥០ថ្មី) " **រដ្ឋធម្មនុញ្ញនេះជាច្បាប់កំពូល នៃព្រះរាជាណាចក្រកម្ពុជា។ ច្បាប់ និងសេចក្តីសម្រេចទាំងឡាយនៃស្ថាប័ននានារបស់រដ្ឋ ត្រូវស្របនឹងរដ្ឋធម្មនុញ្ញជាដាច់ខាត។** "

# (៣៧) ឯករាជ្យភាពនៃអំណាចតុលាការ

- មាត្រា១២៨.-ថ្មី (មាត្រា១០៩ចាស់) " អំណាចតុលាការជាអំណាចឯករាជ្យ ។ អំណាចតុលាការធានារក្សាអនាគតិ និងការពារសិទ្ធិសេរីភាពរបស់ប្រជាពលរដ្ឋ។ អំណាចតុលាការគ្របដណ្តប់ទៅលើរឿងក្តីទាំងអស់រួមទាំងរឿងក្តីរដ្ឋបាលផង។ អំណាចនេះ ត្រូវប្រគល់ឱ្យតុលាការកំពូលនិងសាលាជំរះក្តីគ្រប់ផ្នែកនិងគ្រប់ជាន់ថ្នាក់។ "
- មាត្រា១២៩.-ថ្មី (មាត្រា១១០ចាស់) " ការជំរះក្តីផ្តល់យុត្តិធម៌ ត្រូវធ្វើក្នុងនាមប្រជារាស្ត្រខ្មែរ តាមនីតិវិធីនិងច្បាប់ជាធរមាន។ មានតែចៅក្រមទេដែលមានសិទ្ធិជំរះក្តី។ ចៅក្រមត្រូវបំពេញភារកិច្ចនេះដោយគោរពច្បាប់យ៉ាងម៉ឺងម៉ាត់ និងឱ្យអស់ពីដួងចិត្តនិងសម្បជញ្ញៈរបស់ខ្លួន។ "

# (៣៨) ការការពារ ការគោរពរដ្ឋធម្មនុញ្ញ

- មាត្រា១៣៦.-ថ្មី នៃរដ្ឋធម្មនុញ្ញ " **ក្រុមប្រឹក្សាធម្មនុញ្ញមានសមត្ថកិច្ចធានាការពារការគោរពរដ្ឋធម្មនុញ្ញ បកស្រាយរដ្ឋធម្មនុញ្ញនិងច្បាប់ដែលរដ្ឋសភាបានអនុម័ត និងព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់ហើយ។ ក្រុមប្រឹក្សាធម្មនុញ្ញមានសិទ្ធិពិនិត្យនិងសំរេចអំពីករណីវិវាទកម្មទាក់ទងនឹងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា។** "

# (៣៩) ប្រព័ន្ធសេដ្ឋកិច្ចទីផ្សារ

- មាត្រា៥៦ " ព្រះរាជាណាចក្រកម្ពុជា អនុវត្តប្រព័ន្ធសេដ្ឋកិច្ចទីផ្សារ។ ការរៀបចំនិងការប្រព្រឹត្តទៅនៃប្រព័ន្ធសេដ្ឋកិច្ចនេះ នឹងមានកំណត់ក្នុងច្បាប់។ "
- មាត្រា៦១ " រដ្ឋជំរុញការអភិវឌ្ឍន៍សេដ្ឋកិច្ចគ្រប់វិស័យ ជាពិសេសវិស័យកសិកម្ម សិប្បកម្ម ឧស្សាហកម្ម ចាប់ពីតំបន់ដាច់ស្រយាលដោយយកចិត្តទុកដាក់ទៅលើនយោបាយទឹក ភ្លើង ផ្លូវ និងមធ្យោបាយដឹកជញ្ជូន បច្ចេកទេសទំនើប និងប្រព័ន្ធឥណទាន។ "
- មាត្រា៦២ " រដ្ឋយកចិត្តទុកដាក់ជួយដោះស្រាយមធ្យោបាយផលិត ការពារថ្លៃផលិតផល ជូនកសិករ សិប្បករ និងជួយរកទីផ្សារលក់ផលិតផល។ "
- មាត្រា៦៣ " រដ្ឋយកចិត្តទុកដាក់គ្រប់គ្រងទីផ្សារ ជួយឱ្យជីវភាពរស់នៅរបស់ប្រជាពលរដ្ឋមានកម្រិតសមរម្យ។ "

# (៤០) គោលនយោបាយសង្គមកិច្ច

- ស្ថិតិប្រៀបធៀបតាមឆ្នាំខាងក្រោមនេះ ឆ្លុះបញ្ចាំងនូវការវិវឌ្ឍរីកចម្រើនលើការងារសង្គម ៖

១. អត្រាប្រជាជនស្ថិតក្រោមបន្ទាត់ភាពក្រីក្រ ៖

+ ឆ្នាំ១៩៩៣ ៖ **៣៩%**

+ ឆ្នាំ២០១៨ ៖ **១៣,៥%**

២. ចំណូលមធ្យមប្រចាំឆ្នាំសម្រាប់ប្រជាជនម្នាក់ៗ ៖

+ ឆ្នាំ២០០០ ៖ **២៩៥ដុល្លារអាម៉េរិក**

+ ឆ្នាំ២០២៣ ៖ **១,៩៣២ដុល្លារអាម៉េរិក**

៣.ឧបត្ថម្ភ **គ្រួសារក្រីក្រនិងងាយរងគ្រោះ ៦៩៨,៥៨៥គ្រួសារ** អំឡុងពេលប្រយុទ្ធនឹងកូវីដ១៩ (ខែមិថុនា ២០២០ - ខែតុលា ២០២៣) ចំនួន **៤,៨៥០,៧៦០,៣៣៩,០០០រៀល** ស្មើនឹង **១,២១២,៦៩លានដុល្លារអាម៉េរិក**។

# (៩១) អនុស្សរណៈនៃការព្រមព្រៀង

-ឯកភាពគ្នាដាក់បញ្ចូលបទប្បញ្ញត្តិគ្រឹះមួយចំនួន ដែលមានចែងនៅក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ទៅក្នុងកម្មវិធីសិក្សាកម្រិតបឋមសិក្សា កម្រិតមធ្យមសិក្សាបឋមភូមិ និងកម្រិតមធ្យមសិក្សាទុតិយភូមិ

-ផ្តល់ជំនួយបច្ចេកទេសក្នុងការរៀបចំខ្លឹមសារគោលនិងខ្លឹមសារមេរៀន ដែលពាក់ព័ន្ធនឹងបទប្បញ្ញត្តិគ្រឹះរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ដែលត្រូវដាក់ក្នុងកម្មវិធីសិក្សាទាំងបីកម្រិត

-បោះពុម្ពផ្សាយខ្លឹមសារគោល និងខ្លឹមសារមេរៀន ដែលពាក់ព័ន្ធនឹងបទប្បញ្ញត្តិគ្រឹះរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ទៅក្នុងមុខវិជ្ជាណាមួយដែលសមស្របសម្រាប់កម្មវិធីសិក្សាទាំងបីកម្រិត ក្នុងនោះមានជាអាទិ៍ មេរៀនវិទ្យាសាស្ត្រ-សិក្សាសង្គម និងមេរៀនសីលធម៌-ពលរដ្ឋ

-បច្ចុប្បន្ន ក្រុមប្រឹក្សាធម្មនុញ្ញ និង ក្រសួងអប់រំ យុវជន និងកីឡា បានបញ្ចប់ការងារនេះជាស្ថាពរ ហើយសៀវភៅអប់រំគោលទាំងបីកម្រិត ដែលបានដាក់បញ្ចូលបទប្បញ្ញត្តិគ្រឹះមួយចំនួននៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ក្រសួងអប់រំ យុវជន និងកីឡា ក៏បានបោះពុម្ពផ្សព្វផ្សាយរួចរាល់ហើយដែរសម្រាប់ឆ្នាំសិក្សាថ្មី។



**អនុស្សរណៈនៃការព្រមព្រៀង**

ស្តីពីការដាក់បញ្ចូលបទប្បញ្ញត្តិគ្រឹះមួយចំនួនដែលមានចែងនៅក្នុងរដ្ឋធម្មនុញ្ញ
នៃព្រះរាជាណាចក្រកម្ពុជា ទៅក្នុងកម្មវិធីសិក្សា

**ប្រធានក្រុមប្រឹក្សាធម្មនុញ្ញ** និង **រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

- យល់ឃើញថា រដ្ឋធម្មនុញ្ញគឺជាច្បាប់កំពូលនៃព្រះរាជាណាចក្រកម្ពុជា ដែលបុគ្គលគ្រប់រូបត្រូវគោរពប្រតិបត្តតាម ក្នុងឋានៈជាម្ចាស់វាសនានៃប្រទេសជាតិរបស់ខ្លួន
- យល់ឃើញថា ការយល់ដឹងអំពីគោលការណ៍ធំៗ ដែលមានចែងនៅក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា គឺជាមូលដ្ឋានគ្រឹះចាំបាច់ និងមានសារសំខាន់ ក្នុងការកសាងចំណេះដឹងទូទៅសម្រាប់ប្រជាពលរដ្ឋខ្មែរគ្រប់រូប ក្នុងការពង្រឹងមនសិការស្នេហាជាតិនិងសីលធម៌សង្គម
- យល់ឃើញថា ការបញ្ចូលបទប្បញ្ញត្តិគ្រឹះមួយចំនួន ដែលមានចែងនៅក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ទៅក្នុងកម្មវិធីសិក្សាគឺជាយន្តការមួយដ៏មានប្រសិទ្ធភាពនិងវិសាលភាពទូលំទូលាយក្នុងការកសាងធនធានមនុស្សប្រកបដោយគុណភាព។

ហេតុដូច្នេះ

**ក្រុមប្រឹក្សាធម្មនុញ្ញ** និង **ក្រសួងអប់រំ យុវជន និងកីឡា**

ព្រមព្រៀងដូចខាងក្រោម៖

**ប្រការ១-** *ក្រុមប្រឹក្សាធម្មនុញ្ញ* និង *ក្រសួងអប់រំ យុវជន និងកីឡា* ឯកភាពគ្នាដាក់បញ្ចូលបទប្បញ្ញត្តិគ្រឹះមួយចំនួនដែលមានចែងនៅក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ទៅក្នុងកម្មវិធីសិក្សាកម្រិតបឋមសិក្សា កម្រិតមធ្យមសិក្សាបឋមភូមិ និងកម្រិតមធ្យមសិក្សាទុតិយភូមិ។

**ប្រការ២-** *ក្រុមប្រឹក្សាធម្មនុញ្ញ* ផ្តល់ជំនួយបច្ចេកទេសក្នុងការរៀបចំខ្លឹមសារគោលនិងខ្លឹមសារមេរៀន ដែលពាក់ព័ន្ធនឹងបទប្បញ្ញត្តិគ្រឹះរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ដែលត្រូវដាក់ក្នុងកម្មវិធីសិក្សាទាំងបីកម្រិត។

**ប្រការ៣-** *ក្រសួងអប់រំ យុវជន និងកីឡា* បោះពុម្ពផ្សាយខ្លឹមសារគោលនិងខ្លឹមសារមេរៀន ដែលពាក់ព័ន្ធនឹងបទប្បញ្ញត្តិគ្រឹះរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ទៅក្នុងមុខវិជ្ជាណាមួយដែលសមស្របសម្រាប់កម្មវិធីសិក្សាទាំងបីកម្រិត។

**ប្រការ៤-** *ក្រុមប្រឹក្សាធម្មនុញ្ញ* និង *ក្រសួងអប់រំ យុវជន និងកីឡា* ឯកភាពគ្នាបង្កើតក្រុមការងារចម្រុះមួយដើម្បីបំពេញការងារនេះ ហើយលទ្ធផលដែលសម្រេចបាន ត្រូវមានការឯកភាពជាចុងក្រោយ ដោយប្រធានស្ថាប័នទាំងពីរ។

អនុស្សរណៈនៃការព្រមព្រៀងនេះ ត្រូវបានធ្វើឡើងនៅរាជធានីភ្នំពេញ ថ្ងៃសុក្រ ១០កើត ខែមាឃ ឆ្នាំចសំរឹទ្ធិស័ក ព.ស.២៥៦២ ត្រូវនឹងថ្ងៃទី០១ ខែមីនា ឆ្នាំ២០១៩ ដោយមានភ្ជាប់នូវឧបសម្ព័ន្ធចំនួនមួយ និងមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

**ប្រធានក្រុមប្រឹក្សាធម្មនុញ្ញ** | **រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

ឯកឧត្តម **អ៊ឹម ឈុនលឹម** | ឯកឧត្តមបណ្ឌិតសភាចារ្យ **ហង់ ជួន ណារ៉ុន**

# (៤២) សារាចរស្ដីពីការរៀបចំពិធីគោរពរដ្ឋធម្មនុញ្ញ



**២-ពិធីគោរពរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាក្នុងស្មារតីនៃការរំលឹកខួប "ទិវាប្រកាសរដ្ឋធម្មនុញ្ញ"**

ដោយគោរពអនុវត្តតាមព្រះរាជតម្រិះដ៏ខ្ពង់ខ្ពស់នៃព្រះករុណាជាអម្ចាស់ជីវិតលើត្បូង ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត និងតាមរយៈការស្នើសុំរបស់ក្រុមប្រឹក្សាធម្មនុញ្ញ រាជរដ្ឋាភិបាលកម្ពុជាបានចេញសារាចរលេខ ០១ សរ ចុះថ្ងៃទី៣ ខែមករា ឆ្នាំ២០២៥ ស្ដីពីការរៀបចំប្រារព្ធពិធីគោរពរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ក្នុងស្មារតីនៃការរំលឹកខួប "ទិវាប្រកាសរដ្ឋធម្មនុញ្ញ" ដោយកំណត់យកថ្ងៃទី២៤ ខែកញ្ញា ជារៀងរាល់ឆ្នាំ ដើម្បីប្រារព្ធពិធីគោរពរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា និងបានណែនាំឱ្យគ្រប់ក្រសួង ស្ថាប័ន ត្រូវរៀបចំគណៈប្រតិភូថ្នាក់ដឹកនាំ និងមន្ត្រីរាជការ ចូលរួមប្រារព្ធពិធីគោរពរដ្ឋធម្មនុញ្ញ នៅនីតិបូជនីយដ្ឋាន វិមានរដ្ឋធម្មនុញ្ញ។ ដោយឡែក គ្រប់មន្ទីរ អង្គភាពនានា នៅរាជធានី និងតាមបណ្ដាខេត្ត ត្រូវរៀបចំប្រារព្ធពិធីគោរពរដ្ឋធម្មនុញ្ញ តាមទីតាំង និងលទ្ធភាពជាក់ស្ដែង។



ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ០១ សរ

**សារាចរ**
**ស្ដីពី**
**ការរៀបចំប្រារព្ធពិធីគោរពរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ក្នុងស្មារតីនៃការរំលឹកខួប «ទិវាប្រកាសរដ្ឋធម្មនុញ្ញ»**

រយៈពេលជាង៣០ឆ្នាំនៃការអនុវត្តរដ្ឋធម្មនុញ្ញ ក្រោមម្លប់នៃសុខសន្តិភាពនិងឯកភាពជាតិ អាស្រ័យដោយមាននយោបាយឈ្នះ ឈ្នះ របស់**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** អតីតនាយករដ្ឋមន្ត្រី បច្ចុប្បន្នជាប្រធានព្រឹទ្ធសភា និងជាប្រធានក្រុមឧត្តមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា បានធ្វើឱ្យសម្រេចសមិទ្ធផលធម្មនុញ្ញដ៏ថ្លៃថ្លាលើគ្រប់វិស័យ ជាអាទិ៍ ក្នុងការការពារ ជាតិ សាសនា ព្រះមហាក្សត្រ ការពង្រឹងឯករាជ្យ អធិបតេយ្យជាតិ បូរណភាពទឹកដី អារ្យធម៌អង្គរដ៏បវរ និងធ្វើឱ្យប្រទេសជាតិមានការអភិវឌ្ឍរីកចម្រើនឥតឈប់ឈរ។ ក្នុងបរិបទដ៏ថ្លៃថ្លានេះ វិមានរដ្ឋធម្មនុញ្ញដ៏ល្អវិចិត្រមួយ ត្រូវបានស្ថាបនារួចរាល់ជាស្ថាពរ និងត្រូវបានសម្ពោធកាលពីថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០២៤ ក្រោមព្រះរាជាធិបតីភាពដ៏ខ្ពង់ខ្ពស់នៃ **ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា** ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត ដោយនៅពេលនោះ ព្រះអង្គបានប្រោសប្រទានព្រះបរមរាជឱង្ការថា «វិមានរដ្ឋធម្មនុញ្ញ គឺជានីតិបូជនីយដ្ឋានដ៏ពិសិដ្ឋតំណាងឱ្យ និមិត្តរូបនីតិរដ្ឋ ដែលមាន រដ្ឋធម្មនុញ្ញ ជាកំពូលនៃច្បាប់ផងទាំងឡាយនៅព្រះរាជាណាចក្រកម្ពុជាយើង»។ ហើយព្រះអង្គបានសំណូមពរថា «សមិទ្ធផលធម្មនុញ្ញដ៏ត្រចះត្រចង់សម្រេចបានយ៉ាងដូច្នេះ សូមប្រជាជាតិខ្មែរទាំងមូល តាំងចិត្តក្នុងសម្មាទិដ្ឋិ ប្រកាន់យកជានិច្ចនិរន្តរ៍នូវស្មារតី យើងប្រជារាស្ត្រខ្មែរ រួបរួមគ្នាថែរក្សា ការពារ គោរពខ្ជាប់ខ្ជួនរដ្ឋធម្មនុញ្ញជាច្បាប់កំពូលរបស់ប្រទេស ជានិមិត្តរូបនៃគុណតម្លៃទំនើបរួមផ្សំបុរាណ ជាការសន្យាចំពោះអនាគតរុងរឿងនៃប្រជាជាតិយើង»។

គោរពអនុវត្តតាមព្រះរាជតម្រិះដ៏ខ្ពង់ខ្ពស់នៃ **ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា** ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត និងដោយនាពេលកន្លងមក ក៏ដូចជានាពេលបច្ចុប្បន្ន រាជរដ្ឋាភិបាលបានកំណត់យកថ្ងៃទី២៤ ខែកញ្ញា ជាទិវាប្រកាសរដ្ឋធម្មនុញ្ញដូចមានចែងក្នុងអនុក្រឹត្យស្ដីពីប្រតិទិនឈប់សម្រាកការងាររបស់មន្ត្រីរាជការ និយោជិត កម្មករ ជារៀងរាល់ឆ្នាំ ដើម្បីរំលឹកដល់ថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ១៩៩៣ ដែលជាថ្ងៃប្រកាសឱ្យប្រើរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា។ ក្នុងន័យនេះ រាជរដ្ឋាភិបាលសូមដាក់ចេញនូវវិធានការណែនាំដូចខាងក្រោម៖

១- កំណត់យកថ្ងៃទី២៤ ខែកញ្ញា ជារៀងរាល់ឆ្នាំ ដើម្បីប្រារព្ធ ពិធីគោរពរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា។

១/២

២- គ្រប់ក្រសួង ស្ថាប័ន ត្រូវរៀបចំគណៈប្រតិភូថ្នាក់ដឹកនាំ និងមន្ត្រីរាជការ ចូលរួមប្រារព្ធ ពិធីគោរពរដ្ឋធម្មនុញ្ញ នៅនីតិបូជនីយដ្ឋាន វិមានរដ្ឋធម្មនុញ្ញ នាថ្ងៃទី២៤ ខែកញ្ញា ជារៀងរាល់ឆ្នាំ ដែលត្រូវរៀបចំដោយគណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ-អន្តរជាតិ។ ដោយឡែក គ្រប់មន្ទីរ អង្គភាពនានា នៅរាជធានីនិងតាមបណ្ដាខេត្ត ត្រូវរៀបចំប្រារព្ធ ពិធីគោរពរដ្ឋធម្មនុញ្ញ តាមទីតាំងនិងលទ្ធភាពជាក់ស្ដែង។

៣- គ្រប់ក្រសួង ស្ថាប័ន ស្ថានីយវិទ្យុ ទូរទស្សន៍ជាតិ និងឯកជន ព្រមទាំងបណ្ដាញផ្សព្វផ្សាយនានា ត្រូវប្រើប្រាស់គ្រប់មធ្យោបាយដើម្បីចូលរួមផ្សព្វផ្សាយឱ្យបានទូលំទូលាយនូវរដ្ឋធម្មនុញ្ញ និងប្រវត្តិទាក់ទងនឹងការបង្កើតរដ្ឋធម្មនុញ្ញ ក្នុងគោលដៅបំផុសស្មារតីគោរព ការពារ លើកតម្កើង និងប្រតិបត្តិតាមរដ្ឋធម្មនុញ្ញ ដែលជាច្បាប់កំពូលរបស់ជាតិ។

ទទួលបានសារាចរនេះ ទីស្ដីការគណៈរដ្ឋមន្ត្រី គ្រប់ក្រសួង ស្ថាប័ន គណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ-អន្តរជាតិ និងរដ្ឋបាលរាជធានី ខេត្ត ត្រូវអនុវត្តឱ្យមានប្រសិទ្ធភាពនិងដោយស្មារតីទទួលខុសត្រូវខ្ពស់។

ថ្ងៃ សុក្រ ៤ កើត ខែ បុស្ស ឆ្នាំរោង ឆស័ក ព.ស.២៥៦៨
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៣ ខែមករា ឆ្នាំ២០២៥
**នាយករដ្ឋមន្ត្រី**

**សម្ដេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

**កន្លែងទទួល៖**
- ក្រសួងព្រះបរមរាជវាំង
- ទីស្ដីការគណៈរដ្ឋមន្ត្រី
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- គ្រប់ក្រសួង ស្ថាប័ន
- ខុទ្ទកាល័យសម្ដេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- រដ្ឋបាលរាជធានី ខេត្ត
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

២/២

# (៤៣) ស្តម្ភរដ្ឋធម្មនុញ្ញចម្លង

-ក្រុមប្រឹក្សាធម្មនុញ្ញ បានប្រគល់ស្តម្ភរដ្ឋធម្មនុញ្ញចម្លង ជូនដល់ ឯកឧត្តម លោកជំទាវ អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ដើម្បីយកទៅតម្កល់នៅរាជធានី-ខេត្តទាំង២៥ ទុកជាមង្គលវត្ថុ សម្រាប់ប្រារព្ធពិធីគោរពរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ដែលត្រូវប្រារព្ធធ្វើឡើងនាថ្ងៃទី២៤ ខែកញ្ញា ជារៀងរាល់ឆ្នាំ។

-ស្តម្ភរដ្ឋធម្មនុញ្ញចម្លង គឺជាវត្ថុតំណាងវិមានរដ្ឋធម្មនុញ្ញ ជានីតិបូជនីយដ្ឋានដ៏ពិសិដ្ឋ ដែលនឹងបានជាជំនួយដល់ស្មារតីមន្ត្រីរាជការត្រូវដើរតួនាទីជាគំរូក្នុងការគោរព និងអនុវត្តច្បាប់ ព្រមទាំងក្លាយជាមរតកបេតិកភណ្ឌផ្តល់ប្រយោជន៍ដល់ការសិក្សាខាងប្រវត្តិនីតិសាស្ត្រ និងសិល្បៈវប្បធម៌ ប្រពៃណី។

-ស្តម្ភរដ្ឋធម្មនុញ្ញគំរូដើមដែលក្រុមប្រឹក្សាធម្មនុញ្ញបានចាត់ចម្លងនេះ គឺជាគារវវត្ថុមួយដ៏សំខាន់នៃវិមានរដ្ឋធម្មនុញ្ញ បច្ចុប្បន្នត្រូវបានប្រតិស្ឋាននៅចំមណ្ឌលកណ្តាល នៃខេមរសន្តិមូលសាលនៃវិមានរដ្ឋធម្មនុញ្ញ។ ស្តម្ភរដ្ឋធម្មនុញ្ញនេះមានរាង ៦ជ្រុង ដែលជ្រុងខាងមុខមានចារឹកបុព្វកថា រដ្ឋធម្មនុញ្ញ និង៥ជ្រុងទៀតសម្រាប់ចារឹកយុទ្ធវិធីទាំងប្រាំ នៅក្នុងយុទ្ធសាស្ត្រនយោបាយឈ្នះ-ឈ្នះ នាំមកនូវសន្តិភាពដ៏ថ្លៃថ្លារបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** គឺ បំបែក, ឯកោ, បញ្ចប់, សមាហរណកម្ម, អភិវឌ្ឍន៍ តំណាងដោយព្យញ្ជនៈខ្មែរចំនួនប្រាំតួ គឺ " **ប-ឯ-ប-ស-អ** "។



# ឧបសម្ព័ន្ធ

# ឧបសម្ព័ន្ធទី១

## កាលប្បវត្តិនៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ

| នីតិកាល | កាលបរិច្ឆេទបោះឆ្នោត | គណបក្សឈរឈ្មោះបោះឆ្នោត | អ្នកមានឈ្មោះក្នុងបញ្ជីបោះឆ្នោត | អ្នកបានទៅបោះឆ្នោត | ភាគរយនៃអ្នកបោះឆ្នោត |
|---|---|---|---|---|---|
| ទី1 1993-1998 | 23-28/05/1993 | 20 | 4,764,430 | 4,267,192 | 89.56% |
| ទី2 1998-2003 | 26/07/1998 | 39 | 5,395,595 | 5,057,830 | 93.74% |
| ទី3 2003-2008 | 27/07/2003 | 23 | 6,341,834 | 5,277,494 | 83.22% |
| ទី4 2008-2013 | 27/07/2008 | 11 | 8,125,529 | 6,110,828 | 75.21% |
| ទី5 2013-2018 | 28/07/2013 | 08 | 9,675,453 | 6,735,244 | 69.61% |
| ទី6 2018-2023 | 29/07/2018 | 20 | 8,380,217 | 6,956,900 | 83.02% |
| ទី7 2023-2028 | 23/07/2023 | 18 | 9,710,655 | 8,213,260 | 84.58% |

# ឧបសម្ព័ន្ធទី២

## វិសោធនកម្មរដ្ឋធម្មនុញ្ញទាំង ១១លើក



| កាលបរិច្ឆេទ | កំណត់សម្គាល់នៃវិសោធនកម្ម |
|---|---|
| លើកទី១<br>១៤ កក្កដា ១៩៩៤ | ដើម្បីផ្តល់អំណាចចុះហត្ថលេខាលើព្រះរាជក្រម និងព្រះរាជក្រឹត្យ ជូនប្រមុខរដ្ឋស្តីទី ករណីព្រះមហាក្សត្រប្រឈួន និងព្យាបាលព្រះរោគនៅបរទេស។ |
| លើកទី២<br>០៨ មីនា ១៩៩៩ | ដើម្បីបង្កើតស្ថាប័នព្រឹទ្ធសភា។ |
| លើកទី៣<br>២៨ កក្កដា ២០០១ | ដើម្បីថ្វាយព្រះរាជសិទ្ធិដល់ព្រះមហាក្សត្រក្នុងការបង្កើត និងប្រទានគ្រឿងឥស្សរិយយស ឬមេដាយជាតិជូនមន្ត្រីរាជការស៊ីវិល យោធា និងបុគ្គលនានា។ |
| លើកទី៤<br>១៩ មិថុនា ២០០៥ | ដើម្បីកែសម្រួលកូរ៉ុមសម្រាប់ការប្រជុំរបស់ស្ថាប័ននីតិប្បញ្ញត្តិទាំងពីរ (រដ្ឋសភានិងព្រឹទ្ធសភា)។ |
| លើកទី៥<br>០៩ មីនា ២០០៦ | ដើម្បីកែសម្រួលកូរ៉ុមសម្រាប់ការប្រជុំនិងអនុម័តរបស់ស្ថាប័ននីតិប្បញ្ញត្តិទាំងពីរ (រដ្ឋសភានិងព្រឹទ្ធសភា)។ |

# ឧបសម្ព័ន្ធទី២ (តចប់)

## វិសោធនកម្មរដ្ឋធម្មនុញ្ញទាំង ១១លើក

| កាលបរិច្ឆេទ | កំណត់សម្គាល់នៃវិសោធនកម្ម |
|---|---|
| លើកទី៦<br>១៥ កុម្ភៈ ២០០៨ | ដើម្បីកែសម្រួលការគ្រប់គ្រងរដ្ឋបាលដែនដី នៃព្រះរាជាណាចក្រកម្ពុជា។ |
| លើកទី៧<br>២៣ តុលា ២០១៤ | ដើម្បីផ្តល់ឋានៈជាស្ថាប័នដែលមានចែងក្នុងរដ្ឋធម្មនុញ្ញដល់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត។ |
| លើកទី៨<br>២៧ កុម្ភៈ ២០១៨ | ដើម្បីលើកស្ទួយនូវតម្លៃជាតិខ្មែរ ក្នុងបុព្វហេតុការពារឯករាជ្យជាតិ អធិបតេយ្យជាតិ និងឯកភាពជាតិ ប្រឆាំងនឹងការជ្រៀតជ្រែកពីខាងក្រៅ។ |
| លើកទី៩<br>០៣ វិច្ឆិកា ២០២១ | ដើម្បីកំណត់ឱ្យប្រធានរដ្ឋសភា ប្រធានព្រឹទ្ធសភា នាយករដ្ឋមន្ត្រី និងប្រធានក្រុមប្រឹក្សាធម្មនុញ្ញ ត្រូវតែជាឥស្សរជនដែលមាន "សញ្ជាតិខ្មែរតែមួយគត់"។ |
| លើកទី១០<br>០៦ សីហា ២០២២ | ដើម្បីធានាឱ្យស្ថាប័ននីតិប្រតិបត្តិមានដំណើរការប្រព្រឹត្តទៅដោយរលូន និងប្រកបដោយនិរន្តរភាព នៅគ្រប់កាលៈទេសៈ។ |
| លើកទី១១<br>១៥ កក្កដា ២០២៥ | ដើម្បីលើកកម្ពស់ឧត្តមគតិជាតិ មនសិការស្នេហាជាតិ និងគោលជំហរស្មោះត្រង់ឥតងាករេរបស់ប្រជាពលរដ្ឋខ្មែរគ្រប់រូប ចំពោះជាតិ មាតុភូមិ និងប្រជាជនកម្ពុជានៅគ្រប់កាលៈទេសៈទាំងអស់ ព្រមទាំងរួមចំណែកយ៉ាងសំខាន់ក្នុងការប្រឆាំងនឹងការជ្រៀតជ្រែកពីខាងក្រៅចូលមកក្នុងកិច្ចការផ្ទៃក្នុងរបស់កម្ពុជា ពិសេសការប្រឆាំងនឹងអំពើក្បត់ជាតិ និងអំពើឃុបឃិតគ្នាជាមួយបរទេស ដែលនឹងធ្វើឱ្យប៉ះពាល់ធ្ងន់ធ្ងរដល់វិស័យសន្តិសុខជាតិ សេចក្តីសុខសាន្តរបស់ប្រជាជន និងឧត្តមប្រយោជន៍របស់ប្រទេសជាតិ។ |

# ឧបសម្ព័ន្ធទី៣

ទិន្នន័យលទ្ធផលសម្រេចបាន ២៧ឆ្នាំ របស់ក្រុមប្រឹក្សធម្មនុញ្ញ (គិតត្រឹមថ្ងៃទី១០ ខែមេសា ឆ្នាំ២០២៦) ៖

| | |
|---|---|
| • ថ្វាយមតិព្រះមហាក្សត្រ | ចំនួន ១៦ |
| • បកស្រាយរដ្ឋធម្មនុញ្ញ | ចំនួន ១១ |
| • បកស្រាយច្បាប់ | ចំនួន ១០ |
| • ពិនិត្យធម្មនុញ្ញភាពនៃច្បាប់ | ចំនួន ១០៨ |
| • ការសម្រេចលើវិវាទកម្មនៃការបោះឆ្នោត | ចំនួន ១៤៨ |
| • សំណើមិនចូលសមត្ថកិច្ច ឬខុសទម្រង់ | ចំនួន ៥២ |

# ឯកសារជំនួយស្មារតី

# សម្រង់ខ្លឹមសារ
# សុន្ទរកថារបស់ប្រធានាធិបតីឥណ្ឌា K.R. Narayanan ថ្លែងក្នុងឱកាសបុណ្យខួប៥0ឆ្នាំ នៃសាធារណៈរដ្ឋឥណ្ឌា កាលពីថ្ងៃទី ២៧ ខែមករា ឆ្នាំ២000 លោកបានច្បិចយកទស្សនៈរបស់ Dr. Ambedkar ដែលបានជម្រាបជូនសភាធម្មនុញ្ញ ដូចខាងក្រោម ៖

## សេចក្តីប្រែ

" គណៈសង្ឃព្រះពុទ្ធសាសនា មានទម្រង់ជាស្ថាប័នសភាបែបទំនើប ដែលដំណើរការប្រព្រឹត្តទៅនៃស្ថាប័ននេះ រួមមានយន្តការ ៖ ការដោះស្រាយ និងការសម្រេចសេចក្តី, ការបែងចែកគណៈកម្មការ, ការដាក់ពិន័យ។ល។ ត្រូវបានប្រើប្រាស់ "

## សេចក្តីប្រៀបធៀបក្នុងសង្គមខ្មែរ

អនុលោមតាមការលើកឡើងខាងលើនេះ ជាការឆ្លុះបញ្ចាំងបរិបទនៃស្ថាប័នព្រះពុទ្ធសាសនា គឺមានបែបបទរបៀបរបបស្រដៀងគ្នាទៅនឹងប្រព័ន្ធសភានិយមរបស់លោកខាងលិច ដ្បិតក្នុងស្ថាប័ន ព្រះពុទ្ធសាសនា មានទំនៀមនៃការរៀបចំដំណើរការ និងនីតិវិធីប្រហាក់ប្រហែលនឹងស្ថាប័ននេះ។ ក្នុងបរិបទនេះ សម្រាប់សង្គមខ្មែរ គណៈសង្ឃព្រះពុទ្ធសាសនា (Buddhist Sanghas) ក៏មានទំនងប្រហែលនឹងការលើកឡើងខាងលើនេះផងដែរ ៖

# ១- អំពី Resolutions

នៅក្នុងគណៈសង្ឃព្រះពុទ្ធសាសនារបស់ខ្មែរ មានយន្តការណ៍រំងាប់អធិករណ៍ (Conflict Resolution) ដែលមានលក្ខណៈប្រជាធិបតេយ្យ និងការគោរពសិទ្ធិមនុស្ស តាមទំនៀមរបស់ព្រះសង្ឃ ដោយមានបែងចែកជា ៤ កម្រិតគឺ ៖

- **កម្រិតវត្តអារាម** ៖ ជំនុំសង្ឃដោះស្រាយអធិករណ៍ ដែលមាន**សមាសភាព** ៖ ព្រះចៅអធិការ, ព្រះគ្រូសូធ្យ ឆ្វេង-ស្តាំ, ព្រះវិន័យធរ, លេខាធិការ...។
- **កម្រិតស្រុក** ៖ គឺមានការដោះស្រាយដោយសាលាអនុគណ
- **កម្រិតខេត្ត** ៖ គឺមានការដោះស្រាយដោយសាលាមេគណខេត្ត
- **កម្រិតថ្នាក់ជាតិ** ៖ គឺដោះស្រាយដោយ *ថេរសភា* ដែលជា ស្ថាប័នកំពូលចុងក្រោយ

(របៀបនៃការដោះស្រាយគ្រប់កម្រិត គឺ មានមានលក្ខណៈប្រជាធិបតេយ្យ និងការគោរពសិទ្ធិមនុស្ស ទាំងផ្នែកសមាសភាព និងនីតិវិធី នៃការដោះស្រាយ។)

# ២- អំពី Divisions

នៅក្នុងគណៈសង្ឃព្រះពុទ្ធសាសនាខ្មែរ មានការរៀបចំបែបបទនៃការគ្រប់គ្រងតាមឋានានុក្រមរដ្ឋបាល ស្របតាមមុខងារនីមួយៗ ដែលក្នុងនោះរួមមាន៖

- **ការកសង្ឃ ៖** ជាក្រុមប្រឹក្សាសង្ឃជំនួយដល់គណៈសង្ឃវត្តនីមួយ ដែលត្រូវបានបង្កើតឡើង ដោយភាគច្រើនមានសមាសភាពជាមន្ត្រីសង្ឃមានចំណេះ បទពិសោធន៍ និងមាន មុខងារគ្រប់គ្រង ដូចជាព្រះមេកុដិជាអាទិ៍។ ការកសង្ឃ ត្រូវបោះឆ្នោតជ្រើសរើសប្រធាន មួយរូបជាអ្នកដឹកនាំ តាមបែបប្រជាធិបតេយ្យ។
- **គណៈសង្ឃវត្ត ៖** រួមមាន ព្រះចៅអធិការ, ព្រះគ្រូសូធ្យស្តាំ, ព្រះគ្រូសូធ្យឆ្វេង, ព្រះវិន័យធរ, លេខាធិការ។
- **សាលាអនុគណ ៖** រួមមាន ព្រះអនុគណ, ព្រះវិន័យធរអនុគណ, ព្រះធម្ម ធរអនុគណ, ព្រះសមុហ៍អនុគណ, លេខាធិការអនុគណ។
- **សាលាមេគណ: ៖** រួមមាន ព្រះមេគណ, ព្រះបាឡាត់គណ, ព្រះវិន័យធរគណ, ព្រះធម្មធរគណ, ព្រះសមុហ៍គណ, ព្រះលេខាធិការគណ។
- **គណៈសង្ឃនាយក ៖** រួមមានសម្តេចព្រះសង្ឃនាយក និង សម្តេចព្រះសង្ឃនាយករង ដែលអមដោយព្រះមន្ត្រីសង្ឃ ជាទីព្រះរាជាគណៈគ្រប់ឋានានុក្រម។

# ៣- អំពីទម្រង់នៃការប្រជុំ



ក្នុងព្រះពុទ្ធសាសនា ព្រះពុទ្ធទ្រង់បានពុទ្ធានុញ្ញាតឱ្យមានការប្រជុំសង្ឃ តាមរបៀបនៃការកំណត់កូរ៉ុម សម្រាប់អង្គប្រជុំនៃរដ្ឋសភា ក្នុងសភានិយមបែបទំនើបដែរ ដែលក្នុងនោះមាន ៖

- **ជំនុំសង្ឃ** ( Sessions ) ៖ ជំនុំខ្នាតតូច មានកូរ៉ុមចាប់ពី៤អង្គ យ៉ាងតិច។

ជំនុំសង្ឃនេះ ព្រះពុទ្ធបញ្ញត្តិឲ្យមាន ៥ពួក ៖

**ភិក្ខុសង្ឃចតុវគ្គ** ៖ មានភិក្ខុ ៤ អង្គ
**ភិក្ខុសង្ឃបញ្ចវគ្គ** ៖ មានភិក្ខុ ៥ អង្គ
**ភិក្ខុសង្ឃទសវគ្គ** ៖ មានភិក្ខុ ១០ អង្គ
**ភិក្ខុសង្ឃវីសតិវគ្គ** ៖ មានភិក្ខុ ២០ អង្គ
**ភិក្ខុសង្ឃអតិរេកវីសតិវគ្គ** ៖ មានភិក្ខុលើសពី ២០ អង្គ

( ជំនុំសង្ឃ ប្រារព្ធឡើងដើម្បីព្រមព្រៀងដោយធម៌, យោងបិដកភាគ៨, ទំព័រ ២១២ )

# ៣- អំពីទម្រង់នៃការប្រជុំ (តចប់)



•**សង្គាយនា** (Buddhist council) ជាជំនុំសង្ឃខ្នាតធំ កើតក្រោយព្រះពុទ្ធបរិនិព្វាន គឺធ្វើឡើងដើម្បីប្រជុំផ្ទៀងផ្ទាត់ធម៌/ច្បាប់ ឱ្យបានត្រឹមត្រូវសព្វគ្រប់តាមបែបបទដើម ដែលតាមរបៀបនេះ មានទំនងដូចជា *ការពិនិត្យធម្មនុញ្ញភាព* ក្នុងប្រព័ន្ធនៃការពិនិត្យធម្មនុញ្ញ នាសម័យទំនើប។ គួរបញ្ជាក់ថា ក្នុងប្រវត្តិពុទ្ធសាសនា មានសង្គាយនាចំនួន ៦លើក (សង្គាយនា លើកទី៦ ធ្វើនៅប្រទេសភូមា ឆ្នាំ១៩៥៤)។

ដោយឡែក ទំនៀមនៅស្រុកខ្មែរ មានការទេសនាត្រៃគ្រ៣... ជារបៀបនៃការធ្វើសង្គាយនានោះឯង។

ជាសរុប ទម្រង់ Buddhist Sanghas មានទំនងដូចជា Modern Parliamentary ក្នុងសម័យទំនើប អាស្រ័យដោយគណៈសង្ឃព្រះពុទ្ធសាសនា បានរៀបចំឱ្យមានរបៀបប្រជុំ, នីតិវិធីប្រជុំ, ការកំណត់កូរ៉ុម, ការពិភាក្សា, ការអនុម័ត,... ក្នុងលំនាំស្រដៀងគ្នានឹងការអនុវត្តក្នុងរបបសភាដែរ។